ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

១៩-១០-២០០៤ -ព្រះរាជក្រម នស/រកម/១០០៤/០០៤ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ២៣១៩

២. ព្រះរាជក្រឹត្យ

០៥-១០-២០០៤ -ព្រះរាជក្រឹត្យនស/រកត/១០០៤/៣០០ស្តីពីការតែងតាំងឯកឧត្តម **នរោត្តម ឫទ្ធិ អាននុជាយោធ** ជានាយកខុទ្ទកាល័យសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា បន្ថែមលើតួនាទីបច្ចុប្បន្ន ២៣២១

០៥-១០-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣០២ ស្តីពីការតែងតាំងឯកឧត្តម **ឡៅ សុន្ទារ** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ ២៣២២

០៦-១០-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣០៤ ស្តីពីការតែងតាំងលោកជំទាវ **ហ៊ីម សារាឡា** ជាទីប្រឹក្សា ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ២៣២៣

១២-១០-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣០៧ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូននាយទាហានជាន់ខ្ពស់ ចំនួន ៣១ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចការងារបំរើជាតិមាតុភូមិ ២៣២៤

១២-១០-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣០៨ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ការពារជាតិ** តាមលំដាប់ថ្នាក់ ជូនកងឯកភាពចំនួន ៣៨ កង ចំណុះកងពលតូចលេខ ៧០ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចការងារបំរើជាតិមាតុភូមិ ២៣២៦

១២-១០-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣០៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មជូនលោក **ឆាយ ហ៊ិងលន់**(TSAI HENG-LAN) សញ្ជាតិដើមចិន កើតនៅកោះតៃវ៉ាន់ ប្រទេសចិន ២៣២៨

១២-១០-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣១០ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ជូនលោក **ហូ ទិនយី** (HO WEN-JUI) សញ្ជាតិដើមចិន កើតនៅកោះតៃវ៉ាន់ ប្រទេសចិន ២៣២៩

១២-១០-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣១១ ស្តីពីការតែងតាំងឯកឧត្តម **សំ សុខ** ជាទីប្រឹក្សាសម្តេច **នរោត្តម សិរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ** ២៣៣០

១២-១០-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣១២ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់**ឧត្តមសេនីយ៍ត្រី** ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប	២៣៣១
១២-១០-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣១៣ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់**ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោកវរសេនីយ៍ឯក **ហង្ស ស៊ីធន** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ	២៣៣២
១២-១០-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣១៤ ស្តីពីការតែងតាំងឯកឧត្តម **ឡៀម ឈួយ** ជាទីប្រឹក្សា ផ្ទាល់របស់ឯកឧត្តម **ង៉ោ ម៉ុនស្រ៊ី** អនុប្រធានទី ២ នៃព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ទទួលបន្ទុកពាណិជ្ជកម្ម និងឧស្សាហកម្ម ជំនួស ឯកឧត្តម **ម៉ុំ ឈីម៉ឿន**	២៣៣៣
១២-១០-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣១៥ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០៦រូបជាទីប្រឹក្សា ឯកឧត្តម **ង៉ួន ញ៉ិល** អនុប្រធានទី ២ នៃរដ្ឋសភា នីតិកាលទី ៣	២៣៣៤
១៩-១០-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣១៦ ស្តីពីការតែងតាំងឯកឧត្តម **ឆា ចឺវ៉ាត់** ជាសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី ១ ជំនួស ឯកឧត្តម **ឯក សេរីវឌ្ឍ** ដែលបានតែងតាំងជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហរដ្ឋអាមេរិក	២៣៣៥
១៩-១០-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣១៧ ស្តីពីការតែងតាំង ថ្នាក់ដឹកនាំមជ្ឈមណ្ឌលសកម្មភាពកំចាត់មីន កម្ពុជា (ស៊ីម៉ាក់) ចំនួន ០២រូប	២៣៣៦
១៩-១០-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣១៨ ស្តីពីការតែងតាំងឯកឧត្តម **ស៊ុខ ស៊ុនលី** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកសាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស	២៣៣៧
២០-១០-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣១៩ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០៩រូប ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី	២៣៣៨
២២-១០-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣២០ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **សហមេត្រី** តាមលំដាប់ថ្នាក់ ជូននាយទាហានជាន់ខ្ពស់ នៃកងទ័ពប្រជាជនវៀតណាមចំនួន ០៤ រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ក្នុងការធ្វើសហប្រតិបត្តិការជួយឧបត្ថម្ភដល់កងយោធពលខេមរភូមិន្ទ និងប្រជាពលរដ្ឋកម្ពុជា	២៣៤០
២២-១០-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣២១ ស្តីពីការតម្លើងឋានៈជូនថ្នាក់ដឹកនាំជាន់ខ្ពស់ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចំនួន ០៤ រូប	២៣៤២

២២-១០-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១០០៤/៣២២ស្ដីពីការតែងតាំងលោកជំទាវ **ខៀវ វិនហ៊ាង** ជាអគ្គលេខាធិការរង នៃ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ២៣៤៤

II~ក្រុមប្រឹក្សាធម្មនុញ្ញ

២២-១០-២០០៤ -សេចក្ដីសំរេច លេខ ០៦៥/០០៧/២០០៤ កបធ.ច ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ ២៣៤៥

III~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

១៨-១០-២០០៤ -អនុក្រឹត្យលេខ ៦៨ អនក្រ.បក ស្ដីពីការកែប្រែមាត្រា ៤ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្ដីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី ២៣៤៨

១៩-១០-២០០៤ -អនុក្រឹត្យលេខ ៦៩ អនក្រ.បក ស្ដីពីការបង្កើតតំបន់អភិវឌ្ឍន៍រុនតាឯក ២៣៥១

២០-១០-២០០៤ -អនុក្រឹត្យលេខ ៧០ អនក្រ.បក ស្ដីពីការគ្រប់គ្រងកិច្ចប្រតិបត្តិការបោសសំអាតមីន ដើម្បីរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ២៣៥៦

១៨-១០-២០០៤ -អនុក្រឹត្យលេខ ៥៤៣អនក្រ.តត ស្ដីពីការតែងតាំងសមាជិកនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ២៣៦៥

១៨-១០-២០០៤ -អនុក្រឹត្យលេខ ៥៤៤ អនក្រ.តត ស្ដីពីការផ្លាស់ប្ដូរសមាសភាព តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន នៅក្នុងក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ ២៣៦៨

១៩-១០-២០០៤ -អនុក្រឹត្យលេខ ៥៤៥ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៣៧០

១៩-១០-២០០៤ -អនុក្រឹត្យលេខ ៥៤៦ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៣៧១

២០-១០-២០០៤ -អនុក្រឹត្យលេខ ៥៤៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៣៧២

២០-១០-២០០៤ -អនុក្រឹត្យលេខ ៥៤៨ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ២៣៧៣

២១-១០-២០០៤ -អនុក្រឹត្យលេខ ៥៤៩ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៣៨១

២១-១០-២០០៤ -អនុក្រឹត្យលេខ ៥៥០ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ២៣៨២

២១-១០-២០០៤ -អនុក្រឹត្យលេខ ៥៥១ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ២៣៨៣

២១-១០-២០០៤ -អនុក្រឹត្យលេខ ៥៥២ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ២៣៨៤

២១-១០-២០០៤ -អនុក្រឹត្យលេខ ៥៥៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៣៨៥

២២-១០-២០០៤ -អនុក្រឹត្យលេខ ៥៥៤ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ២៣៨៦

២.សេចក្តីសំរេច

១៨-១០-២០០៤ -សេចក្តីសំរេចលេខ ៦៣ សសរ ស្តីពីការប្រគល់ភារកិច្ចជាសមាជិកក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងជាប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ២៣៨៧

២០-១០-២០០៤ -សេចក្តីសំរេចលេខ ៦៤ សសរ ស្តីពីការអនុញ្ញាតអោយមន្ត្រីរាជការ លាឈប់ពីមុខតំណែង ២៣៨៩

២២-១០-២០០៤ -សេចក្តីសំរេចលេខ ៦៥ សសរ ស្តីពីការចាត់តាំងគណៈកម្មការរៀបចំព្រះរាជពិធីអភិសេកថ្វាយ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ២៣៩០

IV.ការិយាល័យរបស់ក្រសួង

១.លិខិតការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៨-១០-២០០៤ -ប្រកាសលេខ ២០៧ MOC/M 2004 ស្តីពីការដាក់ឱ្យដេញថ្លៃ លើកទី ៤ នូវកូតា សម្លៀកបំពាក់ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៤ ២៣៩៣

២.លិខិតការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

១៨-១០-២០០៤ -ប្រកាសលេខ ៣៣២ ប្រក.កសក ស្តីពីការបង្កើតតំបន់ប្រភពគ្រាប់ពូជឈើនាងនួន ធ្នង់ សុក្រម បេង ពពេល និង គគីរថ្ម នៅក្នុងខេត្តរតនគីរី ២៣៩៧

១៨-១០-២០០៤ -ប្រកាសលេខ ៣៣៣ ប្រក.កសក ស្តីពីការបង្កើតតំបន់ប្រភពគ្រាប់ពូជឈើស្រល់ និងតាត្រាវ គគីរថ្ម នៅក្នុងខេត្តកំពង់ធំ ២៤០៤

១៨-១០-២០០៤ -ប្រកាសលេខ ៣៣៤ ប្រក.កសក ស្តីពីការបង្កើតតំបន់ប្រភពគ្រាប់ពូជឈើក្រញូង និងធ្នង់ នៅក្នុងខេត្តសៀមរាប ២៤០៧

ព្រះរាជក្រម

នស/រកម/១០០៤/០០៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលរដ្ឋសភាបានអនុម័តកាលពី ថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ ២០០៤ នាសម័យប្រជុំលើកទី ៩ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

មាត្រា១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ហើយដែលមានអត្ថបទទាំងស្រុង ភ្ជាប់មកជាមួយនេះ ។

មាត្រា២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

មាត្រា៣.-

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម

ប្រមុខរដ្ឋស្តីទី

ពរល.០៤១០.៣១៩

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា

សុខ អាន

បានចុះលេខ ...៥៤ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៤/៣០០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហមុនី

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើ ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រ កម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងឯកឧត្តម នរណារឫទ្ធិ អានន្ទជាយាថ ជានាយកខុទ្ទកាល័យសម្តេច ក្រុមព្រះ ប្រធានរដ្ឋសភា បន្ថែមលើតួនាទីបច្ចុប្បន្ន ។

មាត្រា២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០០៤

គ្មានព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៧៧. ០៤១០. ៣០២

លេខ: ៦២៣ ចល

ចំលងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ខែតុលា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ីវ៉ា តាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៤/៣០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានតែងតាំងឯកឧត្តម ត្រាំ សុន្ធរ ជាអគ្គនាយក នៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ ។

មាត្រា ២.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣.-

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០៤
ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣.ល. ០៤១០.៣០៤

លេខ ២៤៧ ចល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០០៤
រដ្ឋលេខាធិការគណៈរដ្ឋាភិបាល

សាន់ នាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៤/៣០៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើ ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងលោកជំទាវ ហ៊ីម ឈាន់ឡា ជាទីប្រឹក្សា ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤

គួចព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៣៤. ០៤១០. ៣០៦

បានចម្លងចេញ ... ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជក្រឹត្យ

យើង

នស/រកត/១០០៤/៣០៧

ព្រះបាទសម្តេចព្រះ នរោត្តម សីហមុនី
រាជបរិវង្ស ឧត្តមសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឲ្យដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

សម្រេច

មាត្រា១.-

បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូននាយទាហានជាន់ខ្ពស់ ចំនួន ៣១រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចការងារបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម:-

ក.ឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- ឧត្តមសេនីយ៍ទោ ឡោក ឆាយ	ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភាជាតិ	
២- ឧត្តមសេនីយ៍ទោ អ៊ុក ជឿន	ជំនួយការសម្តេចប្រធានព្រឹទ្ធសភានិងជាមេបញ្ជាការរងកងពលតូចលេខ៧០	
៣-ឧត្តមសេនីយ៍ទោ យ៉ែន ឈាន	នាយករងខុទ្ទកាល័យសម្តេច ប្រធានព្រឹទ្ធសភាជាតិ	
៤-ឧត្តមសេនីយ៍ទោ ចៅ គុណ	ជំនួយការ សម្តេចនាយករដ្ឋមន្ត្រី	
៥-ឧត្តមសេនីយ៍ត្រី ចាន់ ទណ្ណា	មេបញ្ជាការរងនិងជានាយសេនាធិការ កងពលតូច លេខ៧០	
៦-ឧត្តមសេនីយ៍ត្រី ខែម ម៉ា	មេបញ្ជាការរង	កងពលតូចលេខ៧០
៧-ឧត្តមសេនីយ៍ត្រី អៀម និត្យ	មេបញ្ជាការរង	កងពលតូចលេខ៧០
៨-ឧត្តមសេនីយ៍ត្រី ជួន សារី	មេបញ្ជាការរង	កងពលតូចលេខ៧០

៩-ឧត្តមសេនីយ៍ត្រី ឈុន មឿន មេបញ្ជាការរង កងពលតូចលេខ៧០

១០-ឧត្តមសេនីយ៍ត្រី ស៊ីវុធ ស៊ុនិត មេបញ្ជាការរង កងពលតូចលេខ៧០

១១-ឧត្តមសេនីយ៍ត្រី ឈឿន ចាន់ថន មេបញ្ជាការវរសេនាតូចលេខ ១ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា កងពលតូចលេខ៧០

១២-ឧត្តមសេនីយ៍ត្រី ឡៅ សារុន មេបញ្ជាការវរសេនាតូចលេខ២ អង្គរក្ស សម្តេចនាយករដ្ឋមន្ត្រី កងពលតូចលេខ៧០

១៣-ឧត្តមសេនីយ៍ត្រី សុខ ចារុណ មេបញ្ជាការវរសេនាតូចលេខ២ អង្គរក្ស សម្តេចនាយករដ្ឋមន្ត្រី កងពលតូចលេខ៧០

១៤-ឧត្តមសេនីយ៍ត្រី អ៊ុន សាខន មេបញ្ជាការអង្គរក្សសម្តេចក្រុមព្រះ កងពលតូចលេខ៧០

១៥-ឧត្តមសេនីយត្រី គង់ វណ្ណធី លេខាឯកឧត្តម ម៉ុល សារឿន

ខ-ឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១-ឧត្តមសេនីយ៍ត្រី ម៉ិច សុធី មេបញ្ជាការរងវរសេនាតូចលេខ២ អង្គរក្សសម្តេច នាយករដ្ឋមន្ត្រី

២-ឧត្តមសេនីយ៍ត្រី ឡូន ណារិន មេបញ្ជាការរងវរសេនាតូចលេខ២ អង្គរក្សសម្តេច នាយករដ្ឋមន្ត្រី

៣-ឧត្តមសេនីយ៍ត្រី សុខ សុវណ្ណ មេបញ្ជាការរងវរសេនាតូចលេខ២ អង្គរក្សសម្តេច នាយករដ្ឋមន្ត្រី

៤-វរសេនីយ៍ឯក អ៊ួង សំភត់ មេបញ្ជាការរងវរសេនាតូចលេខ១ អង្គរក្សសម្តេច ប្រធានព្រឹទ្ធសភាជាតិ

៥-វរសេនីយ៍ឯក គីម សោភ័ណ្ឌ មេបញ្ជាការរងវរសេនាតូចលេខ១ អង្គរក្សសម្តេច ប្រធានព្រឹទ្ធសភាជាតិ

៦-វរសេនីយ៍ឯក ម៉ក់ សំអូន មេបញ្ជាការរង អង្គរក្សសម្តេច ក្រុមព្រះ ព្រះប្រធានរដ្ឋសភាជាតិ

៧-វរសេនីយ៍ឯក ម៉ែន វណ្ណម៉ូលី នាយរងសេនាធិការ កងពលតូចលេខ៧០

៨-វរសេនីយ៍ឯក ម៉ុន សុខុន នាយរងសេនាធិការ កងពលតូចលេខ៧០

៩-វរសេនីយ៍ទោ ជួន រ៉ា នាយរងសេនាធិការ កងពលតូចលេខ៧០

១០-វរសេនីយ៍ទោ សេង គាណុល នាយរងសេនាធិការ កងពលតូចលេខ៧០

១១-វរសេនីយ៍ទោ អ៊ុំ វណ្ណា នាយរងសេនាធិការ កងពលតូចលេខ៧០

១២-វរសេនីយ៍ទោ លុក អាត់ នាយរងសេនាធិការ កងពលតូចលេខ៧០

១៣-វរសេនីយ៍ទោ ឌុន សាម៉ន នាយរងសេនាធិការ កងពលតូចលេខ៧០

១៤-វរសេនីយ៍ទោ ឌិន ឡុកលី មេបញ្ជាការវរសេនាតូចលេខ៣ (ការពារក្រសួង) កងពលតូចលេខ៧០

១៥-វរសេនីយ៍ទោ ពៅ សុវណ្ណារិទ្ធ មេបញ្ជាការវរសេនាតូចលេខ៤ (អន្តរាគមន៍) កងពលតូចលេខ៧០

១៦-វរសេនីយ៍ទោ សួយ ណារិទ្ធ មេបញ្ជាការវរសេនាតូចលេខ៥(រថក្រោះរថពាសដែក) កងពលតូចលេខ៧០

មាត្រា២.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ តុលា ឆ្នាំ២០០៤

គ្មានព្រះបរមនាម និង គាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

នស/រកត/១០០៤/៣៦០

បានឆ្លងកាត់ ហត្ថលេខា និងព្រះរាជលញ្ឆករ

លេខៈ ២ ៥៥ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាវុធ តាន់

ព្រះរាជក្រឹត្យ

យើង

នស / រកត ១០០៤ / ៣០៥

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

សម្រេច

មាត្រា១.-

បំពាក់គ្រឿងឥស្សរិយយស **ការពារជាតិ** តាមលំដាប់ថ្នាក់ ជូនកងឯកភាពចំនួន ៣៨ កង ចំណុះកងពលតូចលេខ ៧០ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចការងារបំរើជាតិ មាតុភូមិ ដូចមានខាងក្រោម :-

ក-មេដាយមាសការពារជាតិ :

១-បញ្ជាការដ្ឋានកងពលតូចលេខ ៧០

២-សេនាធិការកងពល កងពលតូចលេខ៧០

៣-អង្គភាព វរសេនាតូចលេខ១ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា កងពលតូចលេខ៧០

៤-កងឯកភាពអង្គរក្ស សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភាជាតិ កងពលតូចលេខ៧០

៥-អង្គភាព វរសេនាតូចលេខ២ អង្គរក្ស សម្តេចនាយករដ្ឋមន្ត្រី កងពលតូចលេខ៧០

៦-អង្គភាព វរសេនាតូចលេខ៣ (ការពារក្រសួង) កងពលតូចលេខ៧០

៧-អង្គភាព វរសេនាតូចលេខ៤(អន្តរាគមន៍) កងពលតូចលេខ៧០

៨-អង្គភាព វរសេនាតូចលេខ៥ (រថក្រោះ រថពាសដែក) កងពលតូចលេខ៧០

ខ-មេដាយប្រាក់ការពារជាតិ :

១-ផ្នែកហិរញ្ញវត្ថុ កងពលតូចលេខ៧០

២-ផ្នែកលេខាធិការដ្ឋាន កងពលតូចលេខ៧០

៣-ការិយាល័យទី១ កងពលតូចលេខ៧០

៤-ការិយាល័យទី២ កងពលតូចលេខ៧០

៥-ការយាលយទី៣ កងពលតូចលេខ៧០
៦-ការិយាល័យទី៤ កងពលតូចលេខ៧០
៧-ការិយាល័យទី៥ កងពលតូចលេខ៧០
៨-ការិយាល័យហិរញ្ញ កងពលតូចលេខ៧០
៩-ការិយាល័យបច្ចេកទេស កងពលតូចលេខ៧០
១០-ការិយាល័យអភិវឌ្ឍន៍ កងពលតូចលេខ៧០
១១-មន្ទីរពេទ្យ កងពលតូចលេខ៧០
១២-អង្គភាព កងអនុសេនាធំការពារ កងពលតូចលេខ៧០
១៣-អង្គភាព កងអនុសេនាធំស៊ើបការណ៍ កងពលតូចលេខ៧០
១៤-ផ្នែកលេខាធិការដ្ឋាន វរសេនាតូចលេខ១ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
១៥-ការិយាល័យទី៣ វរសេនាតូចលេខ១ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
១៦-ការិយាល័យហិរញ្ញ វរសេនាតូចលេខ១ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
១៧-អង្គភាពកងអនុសេនាធំអង្គរក្ស វរសេនាតូចលេខ១ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
១៨-អង្គភាពកងអនុសេនាធទី១ វរសេនាតូចលេខ១ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
១៩-អង្គភាពកងអនុសេនាធំទី២ វរសេនាតូចលេខ១ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
២០-អង្គភាពកងអនុសេនាធំទី៣ វរសេនាតូចលេខ១ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
២១-អង្គភាព កងអនុសេនាធំប្រឆាំងភេរវកម្ម វរសេនាតូចលេខ២ អង្គរក្ស សម្តេចនាយករដ្ឋមន្ត្រី
២២-អង្គភាព កងអនុសេនាធំលេខ១ វរសេនាតូចលេខ៣ កងពលតូចលេខ៧០
២៣-អង្គភាព កងអនុសេនាធំលេខ៧ វរសេនាតូចលេខ៤ កងពលតូចលេខ៧០
២៤-អង្គភាព កងអនុសេនាធំទ័ព ពិសេសទី១ វរសេនាតូចលេខ៤ កងពលតូចលេខ៧០
២៥-អង្គភាព កងអនុសេនាធំ DM2 វរសេនាតូចលេខ៥ កងពលតូចលេខ៧០

 គ.មេដាយសេនាការពារជាតិ :

១-ក្រុមតន្ត្រីសម័យ កងពលតូចលេខ៧០
២-អង្គភាព កងអនុសេនាធំ ២៤៦ វរសេនាតូចលេខ២ អង្គរក្ស សម្តេចនាយករដ្ឋមន្ត្រី
៣-អង្គភាព កងអនុសេនាធំលេខ២ វរសេនាតូចលេខ៣ កងពលតូចលេខ៧០
៤-អង្គភាព កងអនុសេនាធំទ័ព ពិសេសទី២ វរសេនាតូចលេខ៤ កងពលតូចលេខ៧០
៥-អង្គភាព កងអនុសេនាធំលេខ១១ វរសេនាតូចលេខ៤ កងពលតូចលេខ៧០

មាត្រា២.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

មាត្រា២.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៤
គូចព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

ពរល. ០៤ ១០. ៣១១ លេខ: ២៥៦.ចល
ដើម្បីចម្លងចែក ហត្ថលេខា និងព្រះរាជលញ្ចករ
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

សូមីដី តាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៤/៣០៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ .-

ផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ជូនលោក ឆាយ ហេងលន់ (TSAI HENG - LAN) សញ្ជាតិដើមចិន កើតថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៥១ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

មាត្រា២ .-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៧៧. ០៤១០. ៣០៥ ១៥១.ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ានិត សាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៤/៣១០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ ..

ផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ជូនលោក **ហូ វិនយី** (HO WEN-JUI) សញ្ជាតិដើមចិន កើតថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧២ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

មាត្រា២ ..

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ ..

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៤

គ្មានព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៤. ០៤១០. ៣៧ លេខៈ ២៥២ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ ១៣ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សារី តាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៤/៣១១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

តែងតាំងឯកឧត្តម **សំ សុខ** ជាទីប្រឹក្សាសម្តេច **នរោត្តម សិរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ២.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពរ.ល. ០៤១០. ៣១៤

លេខៈ ២ ៥៧.ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ ១០ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

... តាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៤/៣១២

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាស អោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/ រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ..

តម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១- លោកវរសេនីយ៍ឯក គង់ ធម្មី អត្តលេខ ០៦៣០ ។

២- លោកវរសេនីយ៍ឯក សេង សិរីបុត្រ អត្តលេខ ០២២០៥ ។

មាត្រា ២..

សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ..

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែតុលាឆ្នាំ ២០០៤

តួខព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពារ.ល. ០៤១០. ៣១៥

លេខ: ២៥៤.ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ខែ តុលា. ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ឆាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៤/៣១៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាស អោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/ រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ .-

តម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោកវរសេនីយ៍ឯក ហង្ស ស៊ីធន អត្តលេខ ០៥១០ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .-

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែតុលា ឆ្នាំ ២០០៤

គួចព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ចារ. ០៤១០. ៣១ លេខ ២៥៩.ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ តុលា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាន់ ខាន់

ព្រះរាជក្រឹត្យ

នស / រកត / ១០០៤ / ៣១៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើរបស់សម្តេច ជ័សុវត្ថិ ជីវ័នមុនីរក្ស ប្រធានព្រឹទ្ធសភាស្តីទី

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងឯកឧត្តម ញ៉ែម គ្រួយ ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ង៉ោ ម៉ិនស្រី អនុប្រធានទី ២ នៃព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ទទួលបន្ទុកពាណិជ្ជកម្ម និងឧស្សាហកម្ម ជំនួសឯកឧត្តម មុំ ឈឹមហ៊ឿន ។

មាត្រា ២: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៤

ត្តូចព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពរ. ០៤១០. ៣១៧

[illegible] ចល
ដើម្បីផ្សព្វផ្សាយ
រាជធានីភ្នំពេញថ្ងៃទី [illegible] ខែ ១០ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៤/៣១៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្តទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងជាទីប្រឹក្សាឯកឧត្តម ងួន ញិល អនុប្រធានទី២ នៃរដ្ឋសភា នីតិកាលទី៣ :

១- ឯកឧត្តម **អ៊ុក ដាមរី** ជាទីប្រឹក្សាអនុប្រធានទី២រដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ

២- ឯកឧត្តម **ម៉ែន ស៊ីផាន់** ជាទីប្រឹក្សាអនុប្រធានទី២រដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ

៣- ឯកឧត្តម **ហ៊ី ចាន់ថន** ជាទីប្រឹក្សាអនុប្រធានទី២រដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ

៤- ឯកឧត្តម **លឹម ស៊ីដេនីន** ជាទីប្រឹក្សាអនុប្រធានទី២រដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ

៥- ឯកឧត្តម **ខួន សុជាតិ** ជាទីប្រឹក្សាអនុប្រធានទី២រដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម **ឡៅ សារឿន** ជាទីប្រឹក្សាអនុប្រធានទី២រដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៤

គួចព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពរល.០៤១០.៣១៥

លេខ: ... ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ... ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

... តាន់

ព្រះរាជក្រឹត្យ

នស / រកត / ១០០៤ / ៣១៦

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់មាត្រា ១១៥ថ្មី និង ១៥៧ ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ ៧៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេច ស៊ីសុវត្ថិ ជីវ័ន់មុនីរ័ក្ស ប្រធានព្រឹទ្ធសភាស្ដីទី

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងឯកឧត្ដម ឆា ចំរ៉ាន់ ជាសមាជិក ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី១ ជំនួសឯកឧត្ដម ឯក សេរីវឌ្ឍ ដែលបានតែងតាំងជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ។

មាត្រា ២: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាត្រាស់បង្គាប់
ប្រមុខរដ្ឋស្ដីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រស.០៤១០.៣៣០

លេខ ៤៦១ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤
[illegible] រាជរដ្ឋាភិបាល
[illegible] តាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៤/៣១៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០២/២៦៨ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ .-

ត្រូវបានតែងតាំង ថ្នាក់ដឹកនាំមជ្ឈមណ្ឌលសកម្មភាពកំចាត់មីន កម្ពុជា (ស៊ីម៉ាក់) ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម ខឹម សោភ័ណ អគ្គនាយក មានឋានៈស្មើ រដ្ឋលេខាធិការ

២- ឯកឧត្តម ហេង រតនា អគ្គនាយករង មានឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា ២ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៤១០.៣៤៩

បានឃើញ និងយល់ស្រប ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ ១ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ាន់ ឆាន់

ព្រះរាជក្រឹត្យ

នស / រកត / ១០០៤/ ៣១៨

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងឯកឧត្តម **សុខ ស៊ុនលីន** ជាទីប្រឹក្សាសម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកសាធារណៈការ និង ដឹកជញ្ជូនមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា ២: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤

ថ្វាយព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពរស-០៤១០:៣៥២

លេខ [illegible] សល

ដើម្បីចម្លងស្មើ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ១០ ឆ្នាំ២០០៤

អគ្គលេខា[illegible]

[illegible]

ព្រះរាជក្រឹត្យ

យើង

នស/រកត/១០០៤/៣១៩

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានតែងតាំង :

១- ឯកឧត្តម **នុត សារាន** ជា **ទីប្រឹក្សាផ្ទាល់** ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកពិនិត្យស្រាវជ្រាវពាក្យបណ្តឹង របស់ប្រជាពលរដ្ឋ និងកិច្ចការតុលាការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- ឯកឧត្តម **នឹម ឌូត** ជា **ទីប្រឹក្សាផ្ទាល់** ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការសង្គមកិច្ច អប់រំ និងសុខាភិបាល បន្ថែមលើមុខងារបច្ចុប្បន្ន។

៣- ឯកឧត្តម **ខិន យន** ជា **ទីប្រឹក្សាផ្ទាល់** ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការពាណិជ្ជកម្ម ផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ថែមលើមុខងារបច្ចុប្បន្ន។

៤- ឯកឧត្តម **សៀង ឡាប្រេស្ស** ជា **ទីប្រឹក្សាផ្ទាល់** ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការ ទំនាក់ទំនង និងសហប្រតិបត្តិការអន្តរជាតិ កិច្ចការដកស្រង់ និងផ្សព្វផ្សាយពត៌មាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

៥- ឯកឧត្តម **ឌុល គឿន** ជា **ទីប្រឹក្សាផ្ទាល់** ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការ ពាណិជ្ជកម្ម ផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

នស.០៤១០.៧២៤

លេខ ៤០៦៥ ចល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង តាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៤/៣៧០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១. -

បំពាក់គ្រឿងឥស្សរិយយស **សហមេត្រី** តាមលំដាប់ថ្នាក់ជូននាយទាហានជាន់ខ្ពស់ នៃកងទ័ពប្រជាជនវៀតណាម ចំនួន ០៤រូប ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ក្នុងការធ្វើសហប្រតិបត្តិការជួយឧបត្ថម្ភដល់កងយោធពលខេមរភូមិន្ទ និង ប្រជាពលរដ្ឋកម្ពុជា ដូចមានរាយនាមខាងក្រោម :

ក. គ្រឿងឥស្សរិយយសសហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ :

- ឯកឧត្តម ឧត្តមសេនីយ៍ឯកបំរុង ហ្វ៊ុង ក្វាងថាញ់ *(Phung Quang Thanh)* ប្រធានអគ្គសេនាធិការកងទ័ពប្រជាជនវៀតណាម ។

ខ. គ្រឿងឥស្សរិយយសសហមេត្រី ថ្នាក់ សេនា :

១. ឯកឧត្តម ឧត្តមសេនីយ៍ត្រី ហ៊ិញ ង៉ុកស៊ឺន *(Huynh Ngoc Son)* មេបញ្ជាការរង និង ជានាយសេនាធិការ យោធភូមិភាគទី ៥

២. ឯកឧត្តម ឧត្តមសេនីយ៍ត្រី ឡេ ម៉ាញ់ *(Le Manh)* មេបញ្ជាការរង យោធភូមិភាគទី ៧

៣. លោកវរសេនីយ៍ឯក ឡេ មិញទន់ *(Le Minh Tuan)* នាយសេនាធិការយោធភូមិភាគទី ៩

មាត្រា ២.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

នស/រកត.០៤១០.៣២៥ **ហត្ថលេខា និងព្រះរាជលញ្ឆករ**

ជា ស៊ីម

លេខៈ ២៧៧០ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈឹង តាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៤ / ៣៧១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

តម្លើងឋានៈជូនថ្នាក់ដឹកនាំជាន់ខ្ពស់ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម ពៅ សាមី	អគ្គលេខាធិការ	មានឋានៈស្មើរដ្ឋមន្ត្រី
២-ឯកឧត្តម ផាន់ ខួន	អគ្គលេខាធិការរង	មានឋានៈស្មើរដ្ឋលេខាធិការ

៣-ឯកឧត្តម ហេង សារឿន អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ

៤-ឯកឧត្តម ម៉ុន ណារិទ្ធិ អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ

មាត្រា ២.-

រាល់បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ

ក្នុងព្រះបរមនាម

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

នស.រកត. ០៤១០-៣៧៦

លេខ ៤២៦ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ. ថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស្វាង ស៊ាន

CPI-2004

ព្រះរាជក្រឹត្យ

យើង

នស/រកត/១០០៤/៣៦៧

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

តែងតាំងលោកជំទាវ ខៀវ រិនហ៊ាង ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រល.០៤១០.៣៦៧

បានលេខ ៣៦៧ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាំង គាន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង
លេខ : ០៨៦/០០៩/២០០៤
ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤
សេចក្ដីសម្រេច
លេខ : ០៦៥/០០៧/២០០៤ កបធ.ច
ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ២៥៣ រស ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៤ របស់សម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតនេះ នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ វេលាម៉ោង ៧:៤៨ ព្រឹក ។

-បានឃើញសេចក្ដីសម្រេចលេខ ០៤០/០០២/២០០១ កបធ.ច ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានប្រកាសថា " ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ " ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែបទបញ្ញត្តិទាំងឡាយណាដែលបានចែងថា " ... ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទី ៣ " ដែលជាទោសសម្លាប់ ក្នុងមាត្រា ២០៩ មាត្រា ៥០០ មាត្រា ៥០៦ និង មាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ដែលត្រូវបានចង្អុលក្នុងមាត្រា ៣ នៃច្បាប់នេះ ។

-បានឃើញសេចក្ដីសម្រេចលេខ ០៤៣/០០៥/២០០១ កបធ.ច ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានប្រកាសថា មាត្រា ៣ នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែល...

រដ្ឋសភាបានអនុម័តយល់ព្រមធ្វើវិសោធនកម្ម កាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់កាលពីថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ស្របនឹងរដ្ឋធម្មនុញ្ញ ។

ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍
ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ការសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះដោយប្រធានរដ្ឋសភា ជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លា ទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ចំណុចដែលបានកែប្រែមានជាអាទិ៍ដូចតទៅ ÷

១-ការកែប្រែអាជ្ញាយុកាល (មាត្រា ៣ ថ្មី) គឺអាជ្ញាយុកាលនៃពាក្យបណ្ដឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ត្រូវបានពន្យារពេលបន្ថែម ៣០ ឆ្នាំ តទៅទៀត (រីឯមាត្រា ៣ ចាស់ អាជ្ញាយុកាលនេះ ត្រូវបានពន្យារពេលបន្ថែម ២០ ឆ្នាំ ទៀតតែប៉ុណ្ណោះ) ។

២-ការកែសម្រួលរចនាសម្ព័ន្ធសាលាជម្រះក្ដី (មាត្រា ៣ ថ្មី) គឺរចនាសម្ព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញដែលមាន ៣ ថ្នាក់ ត្រូវបានសម្រួលមកត្រឹម ២ ថ្នាក់ គឺសាលាដំបូង និង តុលាការកំពូល (តុលាការកំពូលជាកន្លែងទទួលពាក្យបណ្ដឹងឧទ្ធរណ៍ផង និងសម្រេចសេចក្ដីចុងក្រោយផង) ។

៣-ការកែប្រែសមាសភាពនៃអង្គជំនុំជម្រះតុលាការកំពូលឱ្យមានចៅក្រមខ្មែរ ៤ រូប ដែលមួយរូបធ្វើជាប្រធាន និង ចៅក្រមអន្តរជាតិ ៣ រូប ។ អង្គជំនុំជម្រះតុលាការកំពូលនេះ សម្រេចសេចក្ដីបិទផ្លូវតវ៉ា (មាត្រា ៩ ថ្មី) ។

៤-ការកែប្រែអំពីសិទ្ធិពេញលេញរបស់ជនជាប់ចោទ និង អភ័យឯកសិទ្ធិសម្រាប់មន្ត្រីតុលាការ និង មេធាវី ដោយផ្អែកលើអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ (មាត្រា ៤២ ថ្មី) ។

៥-ការកែប្រែបន្ថែមអំពីនីតិវិធីឱ្យបានច្បាស់ថែមទៀតដូចតទៅនេះ : " ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងអំពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពមិនសមស្របនៃនីតិវិធីទាំងអស់នេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកំរិតអន្តរជាតិ " (មាត្រា ២០ ថ្មី មាត្រា២៣ ថ្មី) ។

៦-ការចែងបន្ថែមអំពីវិសាលភាពនៃការលើកលែងទោស និង អនុគ្រោះទោសដែលអាចផ្ដល់ឱ្យមានមុនការអនុម័តច្បាប់នេះ គឺសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ (មាត្រា ៤០ ថ្មី) ។

៧-ការចែងបន្ថែមអំពីល័ក្ខខ័ណ្ឌចៅក្រមដែលត្រូវតែងតាំង ហើយបំរើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវមានបទពិសោធន៍រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សផង (មាត្រា ១០ ថ្មី) ។

៨-សហព្រះរាជអាជ្ញាបរទេស មានសិទ្ធិតែងតាំងសហព្រះរាជអាជ្ញារងបរទេស (មាត្រា ២២ ថ្មី) ។

៩-ការចែងបន្ថែមអំពីភាពមិនអាចរំលោភបំពានបាននៃបណ្ណសារដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល និង ជាទូទៅឯកសារ និង...

សម្ភារៈទាំងអស់ដែលអាចរកបាន ហើយដែលជាកម្មសិទ្ធិរបស់អ្នកទាំងនោះ ឬ ប្រើប្រាស់ដោយជនណាក៏ដោយ ក្នុងរយៈពេលនៃដំណើរការជំនុំជម្រះនេះ (មាត្រា ៤២ ថ្មី) ។

១០-ការកាត់បន្ថយការប្រើប្រាស់ភាសាជាផ្លូវការមកត្រឹម ៣ ភាសា គឺភាសាខ្មែរ ភាសាអង់គ្លេស និង ភាសាបារាំង (មាត្រា ៤៥ ថ្មី) ។

១១-ការកែប្រែដោយលុបចោលបទបញ្ញត្តិដូចតទៅ :

-លុបពាក្យ " មូលនិធិស្ម័គ្រចិត្ត " នៅក្នុងចំណុចទី ២ នៃមាត្រា ៤៤ ចាស់

-លុបចំណុចទី ៣ នៃមាត្រា ៤៤ ចាស់ ។

ចំណុចកែប្រែទាំង ១១ ខាងលើ និងចំណុចកែប្រែដទៃទៀត ពុំមានអ្វីផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

-យល់ឃើញថា ការធ្វើវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនេះ ពុំមានបទបញ្ញត្តិណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១.- ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែប្រែមាត្រា ៤នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

ស ំ រេ ច

មាត្រា ១ .-

មាត្រា ៤នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបានកែប្រែដូចខាងក្រោម :

មាត្រា ៤ ថ្មី : ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសមាសភាពដូចតទៅ :

- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	ប្រធាន
- អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់	អនុប្រធាន
- រដ្ឋមន្ត្រី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	អនុប្រធាន
- រដ្ឋលេខាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ	អនុប្រធាន
- រដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិកអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងការពារជាតិ	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងពាណិជ្ជកម្ម	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងផែនការ	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងបរិស្ថាន	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងព័ត៌មាន	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួង យុត្តិធម៌	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍	សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី	សមាជិក
- ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា	សមាជិក
- តំណាងក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌	សមាជិក
- អគ្គលេខាធិការ គណៈកម្មការជាតិវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣.-

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានសមាសភាពចែងក្នុងមាត្រា ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែតុ១៧ . ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

អនុប្រធានអចិន្ត្រៃយ៍

សុខ អាន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង និងស្ថាប័ន
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ដូចមាត្រា ៣
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការបង្កើតតំបន់អភិវឌ្ឍន៍រុនតាឯក

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បី ការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យ លេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា "អាជ្ញាធរអប្សរា" ឱ្យស្របជាមួយបទបញ្ញត្តិនៃព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១.-

បង្កើតតំបន់អភិវឌ្ឍន៍មួយ ដាក់ឈ្មោះថា " **តំបន់អភិវឌ្ឍន៍រុនតាឯក** " ។

មាត្រា២.-

ទីតាំងនៃតំបន់អភិវឌ្ឍន៍ ស្ថិតនៅក្នុងភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី និងក្នុងភូមិស្វាសង្គ្រាម ឃុំបល្ល័ង្គ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ តំបន់អភិវឌ្ឍន៍នេះមានទំហំដីចំនួន **មួយពាន់ដប់ពីរ ក្បៀសប្រាំ** (១ ០១២, ៥) **ហិកតា** ស្ថិតនៅត្រង់ចន្លោះចំណុចដូចខាងក្រោម :

-ចំណុច **ក** ខ្សែរយៈបណ្ដោយ **៣៩៤ ០០០** និងខ្សែរយៈទទឹង **១ ៤៩២ ០០០**

-ចំណុច **ខ** ខ្សែរយៈបណ្ដោយ **៣៩៨ ៥០០** និងខ្សែរយៈទទឹង **១ ៤៩២ ០០០**

-ចំណុច **គ** ខ្សែរយៈបណ្ដោយ **៣៩៨ ៥០០** និងខ្សែរយៈទទឹង **១ ៤៨៩ ៥២០**

-ចំណុច **ឃ** ខ្សែរយៈបណ្ដោយ **៣៩៤ ០០០** និងខ្សែរយៈទទឹង **១ ៤៨៩ ៨០០**

មាត្រា៣.-

តំបន់អភិវឌ្ឍន៍នេះត្រូវបានប្រគល់ជូនអាជ្ញាធរអប្សរា ជាអ្នកគ្រប់គ្រង និងរៀបចំការអភិវឌ្ឍន៍តាមទិសដៅរបស់រាជរដ្ឋាភិបាល និងក្នុងការងារដោះស្រាយបញ្ហាសំណង់លំនៅដ្ឋានថ្មីរបស់ប្រជាពលរដ្ឋ ដែលកំពុងរស់នៅ ក្នុងតំបន់១ និងតំបន់២ នៃរមណីយដ្ឋានអង្គរសព្វថ្ងៃ ។

មាត្រា៤.-

អាជ្ញាធរអប្សរា ជាអ្នកទទួលបន្ទុករៀបចំប្លង់អភិវឌ្ឍន៍តំបន់នេះ ដើម្បីបង្កលក្ខណៈងាយស្រួល ជូនដល់ប្រជាពលរដ្ឋ ដែលត្រូវចេញពីតំបន់អង្គរទៅរស់នៅក្នុងតំបន់នោះ អាចរស់នៅបានយ៉ាងសមរម្យនិង មានការអភិវឌ្ឍន៍នាពេលអនាគត ។

មាត្រា៥.-

អាជ្ញាធរអប្សរាជាអ្នកទទួលបន្ទុកចុះអង្កេតរាល់ការកាន់កាប់ និងប្រើប្រាស់ដី នៅក្នុងតំបន់នេះ របស់ប្រជាពលរដ្ឋ ហើយសហការជាមួយអាជ្ញាធរដែនដី ដើម្បីដោះស្រាយគោលនយោបាយឱ្យបាន សមស្រប ។

មាត្រា៦.-

អនុក្រឹត្យនេះ និរាករណ៍រាល់លិខិតពាក់ព័ន្ធនឹងការកាន់កាប់ដីធ្លីក្នុងតំបន់នេះ ដូចមានភ្ជាប់ប្លង់ក្នុងឧបសម្ព័ន្ធ ១ ។

មាត្រា៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០៤

សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- កាលប្បវត្តិ-ឯកសារ



ភូជ	X	Y
ក	៣៩៤០០០	១៤៩២០០០
ខ	៣៩៨៥០០	១៤៩២០០០
គ	៣៩៨៥០០	១៤៨៩៥២០
ឃ	៣៩៤០០០	១៤៨៩៨០០


Legend
Phum
Zoning
Zone 1
Zone 2
Zone 3
Zone 4
0 1,250 2,500 5,000 7,500 10,000 Meters
1:150,000

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការគ្រប់គ្រងកិច្ចប្រតិបត្តិការបោសសំអាតមីន ដើម្បីរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមិនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦១ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការតែងតាំងសមាសភាព អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយ សារមីន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយ សារមីន
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៤

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ កំណត់ការគ្រប់គ្រងកិច្ចប្រតិបត្តិការបោសសំអាតមីន ដើម្បីរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ដោយកំណត់បន្ថែមនូវតួនាទីរបស់អាជ្ញាធរគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ហៅកាត់ថា អាជ្ញាធរមីន និងតួនាទីអាជ្ញាធរ ខេត្តក្រុងពាក់ពន្ធ័ ព្រមទាំងអង្គការអភិវឌ្ឍន៍នានា ដើម្បីជួយសំរួលដល់ដំណើរការ បោសសំអាតមីន ផ្នែកសេដ្ឋកិច្ច-សង្គម។

ជំពូកទី ២

ការទទួលខុសត្រូវរបស់អាជ្ញាធរមីន

មាត្រា ២.-

អាជ្ញាធរមីន មានសមត្ថកិច្ចត្រួតពិនិត្យគ្រប់សកម្មភាពកំចាត់មីនទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានានូវប្រសិទ្ធភាព សកម្មភាពបោសសំអាតមីន ដូចមានកំណត់ក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រនិងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ព្រមទាំងផែនការដទៃទៀតរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុង ព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន។

មាត្រា ៣.-

អាជ្ញាធរមីន សំរបសំរួលសកម្មភាពកំចាត់មីនជាមួយក្រសួង ស្ថាប័ន និង ណែនាំបច្ចេកទេសអាជ្ញាធរដែនដីពាក់ព័ន្ធ ក្នុងការអនុវត្តយុទ្ធសាស្ត្រ និង ផែនការជាតិនៃសកម្មភាពកំចាត់មីន ដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះ។

មាត្រា ៤.-

អាជ្ញាធរមីន ពិនិត្យលើសំណើតាមអាទិភាព ដែលស្នើឡើងដោយអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីរៀបចំផែនការជាតិ រយៈពេលខ្លី មធ្យម និង វែង សំរាប់សកម្មភាពកំចាត់មីន។

មាត្រា ៥.-

អាជ្ញាធរមីន ត្រូវរៀបចំ និង ត្រួតពិនិត្យការអនុវត្តគោលការណ៍ណែនាំ ថ្នាក់ជាតិផ្នែកសេដ្ឋកិច្ច-សង្គម សំរាប់សកម្មភាពបោសសំអាតមីន នៅតាមខេត្តក្រុងពាក់ព័ន្ធ ។

មាត្រា ៦.-

គ្រប់សកម្មភាពបោសសំអាតមីន ដែលបានដាក់ចេញជាផែនការនៅក្នុងខេត្តក្រុងពាក់ព័ន្ធនីមួយៗ ត្រូវផ្ញើមកអាជ្ញាធរមីន ដើម្បីសម្រេចជាផ្លូវការមុនចាប់ផ្តើមអនុវត្ត លើកលែងតែករណីចាំបាច់ ក្នុងទិសដៅអភិវឌ្ឍន៍មូលដ្ឋានបន្ទាន់បំផុត ដែលត្រូវអនុម័តដោយថ្នាក់ដឹកនាំខេត្តក្រុង រួចធ្វើសេចក្តីរាយការណ៍មកអាជ្ញាធរមីនជាក្រោយ ។

ជំពូកទី ៣
ការទទួលខុសត្រូវរបស់អាជ្ញាធរខេត្តក្រុង

មាត្រា ៧.-

អភិបាលខេត្តក្រុង ត្រូវទទួលខុសត្រូវ លើការជ្រើសរើសដីអាទិភាព សំរាប់ដោះមីននៅក្នុងដែនដីខេត្តក្រុងរបស់ខ្លួន ។

មាត្រា ៨.-

អភិបាលខេត្តក្រុង ត្រូវទទួលខុសត្រូវ រាល់សកម្មភាពបោសសំអាតមីននៅក្នុងដែនដីខេត្តក្រុង ដោយៈ

- អនុវត្តតាមយុទ្ធសាស្ត្រជាតិស្តីពីសកម្មភាពកំចាត់មីន ដែលដាក់ចេញដោយអាជ្ញាធរមីន
- រៀបចំផែនការរបស់ខ្លួន ដោយអនុលោមតាមភាពចាំបាច់ជាក់ស្តែង និង ផ្សារភ្ជាប់ជាមួយផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់ ឬ ខេត្តក្រុង ។

មាត្រា ៩.-

អភិបាលខេត្តក្រុង ត្រូវធានាលើដីដែលជ្រើសរើសសំរាប់ដោះមីន ត្រូវបែងចែក និងប្រើប្រាស់ឱ្យបានត្រឹមត្រូវ និង មានតម្លាភាព សមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ដោយឡែក នីតិវិធីនៃការបែងចែកដីជូនប្រជាពលរដ្ឋក្រីក្រ ដែលខ្វះដី និងគ្មានដី ត្រូវអនុលោមតាមអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

មាត្រា ១០.-

អភិបាលខេត្តក្រុង ត្រូវរៀបចំផែនការសកម្មភាពបោសសំអាតមីនប្រចាំឆ្នាំរបស់ខ្លួន ទៅតាមចំណាត់អាទិភាព រួចផ្ញើមកអាជ្ញាធរមីន។

មាត្រា ១១.-

អភិបាលខេត្តក្រុង ត្រូវចាត់វិធានការដោយរួសរាន់ លើរាល់សំណើលើកឡើងដោយ គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្តក្រុង។

មាត្រា ១២.-

អភិបាលខេត្តក្រុង ត្រូវរៀបចំបង្កើតយន្តការ ដែលជាបណ្តាញ ពិគ្រោះយោបល់ជាប្រចាំដើម្បីគ្រប់គ្រងសកម្មភាពកំចាត់មីនទាំងអស់ ក្នុងទិសដៅបង្កើនល្បឿនសកម្មភាពបោសសំអាតមីន និងកាត់បន្ថយអត្រាគ្រោះថ្នាក់ដោយសារមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះឱ្យបានជាអតិបរមា។

ជំពូកទី ៤

គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្តក្រុង

មាត្រា ១៣.-

អភិបាលខេត្តក្រុង ត្រូវបង្កើតគណៈកម្មាធិការសកម្មភាពកំចាត់មីន ក្នុងខេត្តក្រុងរបស់ខ្លួន ដោយប្រើប្រាស់ត្រារបស់ខេត្តក្រុងផ្ទាល់។ ដោយឡែកចំពោះអនុប្រធានអចិន្ត្រៃយ៍ អភិបាលខេត្តក្រុង ត្រូវជ្រើសរើសក្នុងចំណោមប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តក្រុង ប្រធានមន្ទីរផែនការខេត្តក្រុង និង ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រុង។

មាត្រា ១៤.-

គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្តក្រុង ត្រូវមានភារកិច្ចដូចតទៅ :

- ជ្រើសរើសដីចំការមីនសំរាប់បោសសំអាតអោយស្របទៅនឹង :
    - សមាហរណកម្មនៃយុទ្ធសាស្ត្រជាតិ ផែនការ និង អាទិភាពជាតិដទៃទៀត ដែលពាក់ព័ន្ធ
    - ធានានូវប្រសិទ្ធភាពនៃការផ្សារភ្ជាប់រវាងផែនការអភិវឌ្ឍខេត្តក្រុង និង ក្រុមប្រឹក្សាឃុំសង្កាត់

- ធ្វើអោយមានតម្លាភាពនៃដំណើរការដោះមីន ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ភ្នាក់ងារដោះមីន និង អង្គការអភិវឌ្ឍនានា។

- ជ្រើសរើសដីចំការមីនអាទិភាពដោយ

  - អនុវត្តទៅតាមគោលការណ៍ជាតិផ្នែកសេដ្ឋកិច្ច-សង្គម សំរាប់សកម្មភាពបោសសំអាតមីន ដែលចេញដោយអាជ្ញាធរមីន
  - សហការជាមួយគណៈកម្មាធិការបែងចែក និងប្រើប្រាស់ដីខេត្តក្រុង។

- សម្រេចផែនការប្រចាំឆ្នាំរបស់ខេត្តក្រុង ដោយ

  - រៀបចំផែនការអាទិភាពលំអិតមួយ ដែលទាក់ទងទៅនឹងផែនការបោសសំអាតមីនខេត្តក្រុង
  - ដាក់សេចក្តីព្រាងនោះជូនមកអាជ្ញាធរមីន។

មាត្រា ១៥.-

សមាសភាពនៃគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង រួមមាន:

- អភិបាល ឬ អភិបាលរងខេត្តក្រុង	ប្រធាន
- ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដី	អនុប្រធាន
- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ	អនុប្រធាន
- ប្រធានមន្ទីរផែនការ	អនុប្រធាន
- តំណាងអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន	សមាជិក
- មេបញ្ជាការ នៃតំបន់ប្រតិបត្តិការសឹករង	សមាជិក
- ស្នងការនគរបាល	សមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថ	សមាជិក
- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	សមាជិក
- ប្រធានមន្ទីរបរិស្ថាន	សមាជិក
- ប្រធានមន្ទីរកិច្ចការនារី	សមាជិក
- ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	សមាជិក
- ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
- ប្រធានមន្ទីរអប់រំ យុវជន និងកីឡា	សមាជិក
- ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន	សមាជិក

- ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- ប្រធានមន្ទីរទេសចរណ៍ សមាជិក
- ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
- ប្រធានមន្ទីរធម្មការ និងសាសនា សមាជិក
- ប្រធានមន្ទីរពត៌មាន សមាជិក
- តំណាងយោធភូមិភាគ ឬកងពលដែលបោះទីតាំងក្នុងខេត្ត ក្រុង សមាជិក
- អភិបាលស្រុក ខ័ណ្ឌពាក់ព័ន្ធ សមាជិក
- ប្រធានការិយាល័យរដ្ឋបាលមូលដ្ឋាន សមាជិក
- ប្រតិបត្តិករដោះមីន ដែលធ្វើប្រតិបត្តិការក្នុងខេត្ត ក្រុង សមាជិក
- តំណាងភ្នាក់ងារអង្គការអន្តរជាតិ ដែលធ្វើប្រតិបត្តិការក្នុងខេត្ត ក្រុង សមាជិក

សមាសភាពនៃគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង ត្រូវបានតែងតាំងដោយអភិបាលខេត្តក្រុង លើកលែងតែតំណាងមកពីអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន ប្រតិបត្តិករដោះមីន និង តំណាងភ្នាក់ងារអង្គការអន្តរជាតិ ដែលនឹងត្រូវតែងតាំងដោយស្ថាប័នសាមី។

ប្រធាននៃគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង អាចអញ្ជើញតំណាងស្ថាប័នពាក់ព័ន្ធដទៃទៀត ដែលមានសកម្មភាពពាក់ព័ន្ធ អោយចូលរួមជាសមាជិក ឬ សមាជិកសង្កេតការណ៍ ដោយផ្អែកលើតម្រូវការចាំបាច់ នៃសកម្មភាពបោសសំអាតមីននីមួយៗ។

មាត្រា ១៦.-

គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង ត្រូវបង្កើតក្រុមការងារបច្ចេកទេសអចិន្ត្រៃយ៍មួយជាសេនាធិការ និងមានក្រុមការងារច្រើនសំរាប់ប្រតិបត្តិការ នៅតាមសហគមន៍ដែលប៉ះពាល់ដោយសារមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។

ជំពូកទី ៥

ក្រុមការងារផែនការសកម្មភាពកំចាត់មីន

មាត្រា ១៧.-

ក្រុមការងារផែនការសកម្មភាពកំចាត់មីន គឺជាក្រុមបច្ចេកទេសអចិន្ត្រៃយ៍ សំរាប់ជួយដល់គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង។ ក្រុមការងារនេះ ត្រូវបានតែងតាំងដោយអភិបាលខេត្ត ក្រុង។

មាត្រា ១៨.-

សមាសភាពនៃក្រុមការងារផែនការសកម្មភាពកំចាត់មីន ត្រូវបានជ្រើសរើសក្នុងចំណោម មន្ត្រី-បុគ្គលិក មកពីស្ថាប័នពាក់ព័ន្ធក្នុងខេត្ត ក្រុង ដែលជាសមាជិកនៃគណៈកម្មាធិការ សកម្មភាពកំចាត់មីនខេត្ត ក្រុង និង ភាគីពាក់ព័ន្ធដទៃទៀតក្នុងសកម្មភាពកំចាត់មីនខេត្ត ក្រុង។

មាត្រា ១៩.-

ក្រុមការងារផែនការសកម្មភាពកំចាត់មីន ត្រូវអនុវត្តនូវសេចក្ដីសំរេចនានា ដែលចេញដោយគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង។

មាត្រា ២០.-

ក្រុមការងារផែនការសកម្មភាពកំចាត់មីន ត្រូវពិនិត្យអង្កេតនៅតាមមូលដ្ឋានផ្ទាល់ ដើម្បីកំណត់ចំការមីនសំរាប់ដោះ ត្រួតពិនិត្យដំណើរការដោះមីន និងក្រោយពេលដោះមីន ស្របតាមគោលការណ៍ជាតិផ្នែកសេដ្ឋកិច្ច-សង្គម សំរាប់សកម្មភាពបោសសំអាតមីន។

មាត្រា ២១.-

ក្រុមការងារផែនការសកម្មភាពកំចាត់មីន ត្រូវដាក់សំណើទៅគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្តក្រុង នូវផែនការការងារប្រចាំឆ្នាំពេញលេញមួយ ដោយរួមបញ្ចូលគ្រប់ផែនការសកម្មភាពបោសសំអាតមីននៅក្នុងខេត្ត ក្រុង។

មាត្រា ២២.-

ក្រុមការងារផែនការសកម្មភាពកំចាត់មីន ត្រូវរាយការណ៍ដោយផ្ទាល់ទៅគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង។

ជំពូកទី ៦
ក្រុមការងារសកម្មភាពកំចាត់មីន ថ្នាក់ស្រុក ខណ្ឌ

មាត្រា ២៣.-

ក្រុមការងារសកម្មភាពកំចាត់មីនថ្នាក់ស្រុក ខណ្ឌ ត្រូវបានតែងតាំងដោយអភិបាលខេត្ត ក្រុង។

មាត្រា ២៤.-

សមាសភាពនៃក្រុមការងារសកម្មភាពកំចាត់មីនថ្នាក់ស្រុក ខ័ណ្ឌ រួមមានសមាជិកមកពីការិយាល័យពាក់ព័ន្ធជុំវិញស្រុក ខ័ណ្ឌ និង ភាគីពាក់ព័ន្ធនឹងសកម្មភាពបោសសំអាតមីនផ្សេងទៀត នៅក្នុងស្រុក ខ័ណ្ឌ ដោយមានអភិបាលស្រុក ខ័ណ្ឌ ជាប្រធាន ។

មាត្រា ២៥.-

ក្រុមការងារសកម្មភាពកំចាត់មីនថ្នាក់ស្រុក ខ័ណ្ឌ ត្រូវផ្តល់ជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការជ្រើសរើសដីចំការមីន ដើម្បីតភ្ជាប់ការបោសសំអាតមីន និង ដើម្បីជ្រើសរើស អ្នកទទួលផលឱ្យបានត្រឹមត្រូវទៅនឹងផែនការប្រើប្រាស់ដី ។

មាត្រា ២៦.-

ក្រុមការងារសកម្មភាពកំចាត់មីនថ្នាក់ស្រុក ខ័ណ្ឌ ត្រូវដាក់សំណើផែនការការងារប្រចាំឆ្នាំ សំរាប់គ្រប់សកម្មភាពបោសសំអាតមីន ក្នុងស្រុក ខ័ណ្ឌ ទៅគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង ។

ជំពូកទី ៧
ប្រភពធនធាន

មាត្រា ២៧.-

ប្រភពធនធាន និង ថវិកាទ្រទ្រង់ដល់យន្តការសេដ្ឋកិច្ច-សង្គម សំរាប់ការគ្រប់គ្រងកិច្ចប្រតិបត្តិការបោសសំអាតមីន ត្រូវបានបង្កើតឡើងតាមរយៈ :

- ថវិកាជាតិ
- ប្រភពធនធានក្នុង និង ក្រៅប្រទេស ឬ បានមកពីអង្គការផ្តល់ជំនួយអន្តរជាតិនានា ។

សេចក្តីលំអិតស្តីពីកិច្ចសំរបសំរួលហិរញ្ញវត្ថុ និងត្រូវមានចែងដោយឡែកនៅក្នុងគោលការណ៍ណែនាំសេដ្ឋកិច្ច-សង្គម ថ្នាក់ជាតិ ដូចមាននៅត្រង់មាត្រា ២៨ នៃអនុក្រឹត្យនេះ ។

ជំពូកទី ៨

អវសានប្បញ្ញត្តិ

មាត្រា ២៨.-

អាជ្ញាធរមីនត្រូវរៀបចំ និង ផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវគោលការណ៍ណែនាំថ្នាក់ជាតិផ្នែក សេដ្ឋកិច្ច-សង្គម សំរាប់សកម្មភាពបោសសំអាតមីន និង បទប្បញ្ញត្តិផ្សេងៗទៀត សំរាប់អនុវត្តអនុក្រឹត្យនេះ ។

មាត្រា ២៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អាជ្ញាធរមីន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន អភិបាលខេត្ត ក្រុងពាក់ព័ន្ធទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះ ហត្ថលេខា តទៅ ។

ភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] , ឆ្នាំ ២០០៤

ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ដូចមាត្រា ១៥ និង ៣០
-ឯកសារ-កាលប្បវត្តិ
-រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

៥៤៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងសមាជិកនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ អនក្រ.បក ចុះថ្ងៃទី ខែ ឆ្នាំ ២០០៤ ស្តីពីការកែប្រែមាត្រា ៤នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី

សំរេច

មាត្រា ១ .-

សមាសភាពនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានរាយនាម ដូចតទៅ :

- ឯកឧត្តម **អ៊ឹម ឈុនលឹម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន
- ឯកឧត្តម **ហេង វង្សប៊ុនឆាត** អនុប្រធាន នៃក្រុមប្រឹក្សាអ្នកច្បាប់ អនុប្រធាន
- ឯកឧត្តម **ចាន់ សារុន** រដ្ឋមន្ត្រី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន
- ឯកឧត្តម **អ៊ិន ចន្ធា** រដ្ឋលេខាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ អនុប្រធាន
- ឯកឧត្តម **ជា សុផារ៉ា** រដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិកអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- ឯកឧត្តម **ម៉ុន អ៊ុយ** រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- ឯកឧត្តម **ញ៉ាំ សុខា** រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ សមាជិក
- ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការ នៃក្រសួងការពារជាតិ សមាជិក
- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **ឡិក ម៉ុង** រដ្ឋលេខាធិការ នៃក្រសួងពាណិជ្ជកម្ម សមាជិក
- ឯកឧត្តម **អ៊ិត ប្រាំង** រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
- ឯកឧត្តម **អ៊ូ ឡិហាក** រដ្ឋលេខាធិការ នៃក្រសួងផែនការ សមាជិក
- ឯកឧត្តម **យិន គឹមសាន** រដ្ឋលេខាធិការ នៃក្រសួងបរិស្ថាន សមាជិក
- ឯកឧត្តម **ម៉ៅ ពិន** រដ្ឋលេខាធិការ នៃក្រសួងធនធានទឹក និងឧតុនិយម សមាជិក
- ឯកឧត្តម **គាន់ ស៊ីម៉ាន់** រដ្ឋលេខាធិការ នៃក្រសួងព័ត៌មាន សមាជិក
- ឯកឧត្តម **ហ៊ី សោភា** រដ្ឋលេខាធិការ នៃក្រសួង យុត្តិធម៌ សមាជិក
- ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- ឯកឧត្តម **អ៊ុន ស៊ីយ៉ុន្ណា** រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ សមាជិក
- លោកជំទាវ **ឃឹម ចំរើន** រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី សមាជិក
- ឯកឧត្តម **ឱម យ៉ិនទៀង** ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សមាជិក
- ឯកឧត្តម **ឌូច ស៊ិងតាណា** សមាជិកនៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សមាជិក
- ឯកឧត្តម **សួន សិទ្ធី** អគ្គលេខាធិការ គណៈកម្មការជាតិវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

មាត្រា ២ .-

អនុក្រឹត្យ លេខ ៤០៥ អនក្រ.គត. ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការតែងតាំងសមាជិកនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

គោលនយោបាយដីធ្លី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ .-

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានសមាសភាពចែងក្នុងមាត្រា ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ៩ ៧ . ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

អនុប្រធានអចិន្ត្រៃយ៍

សុខ អាន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង និងស្ថាប័ន
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ដូចមាត្រា ៣
- ឯកសារ - កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤៤ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការផ្លាស់ប្ដូរសមាសភាព តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន នៅក្នុងក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពី លក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៣៧៤ អនក្រ.តត ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៣ ស្ដីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

សម្រេច

មាត្រា ១ .-

ត្រូវបានតែងតាំង លោក **ហ៊ី អានទ័រនិច** ជាសមាជិកថ្មី តំណាងក្រសួង សាធារណការ និង ដឹកជញ្ជូន ក្នុងក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ ជំនួសឯកឧត្តម **សំ សុខ** ដែលត្រូវបានបញ្ចប់ភារកិច្ច ។

មាត្រា ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ខែ តុលា ឆ្នាំ២០០៤

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៤៤...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យ លេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- យោងតាមសំណើរបស់លោកជំទាវទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

សម្រេច

មាត្រា ១.-

ត្រូវបានតែងតាំង លោក **រស់ សុខ** ជាជំនួយការ លោកជំទាវ **ម៉ែន សំអន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច មានឋានៈស្មើ **អគ្គនាយករង** ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៩ ៣ ឆ្នាំ ២០០៤

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៥៤៦.អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤/ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១.-

ត្រូវបានតែងតាំងលោក **ឃឹម សុគន្ធី** ជាជំនួយការអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល មានឋានៈស្មើប្រធាននាយកដ្ឋាន ។

មាត្រា២.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

តែងតាំងលោក **សេង ហួត** ជាជំនួយការ សម្តេច **នរោត្តម សិរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយករង ជំនួសលោក **ម៉ៅ រតនា** ដែលត្រូវបានទទួលតំណែងថ្មី ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

******

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នាយនគរបាល នាយនគរបាលរង និងពលនគរបាលចំនួន ១៩២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម:

ក / <u>មេដាយមាសការងារ ចំនួន ៧១ រូប</u>

១- លោកឧត្តមសេនីយ៍ត្រី	អ៊ុក	សារ៉ុត	ប្រធាននាយកដ្ឋានបំភ័ន្តអក្សរ
២- លោកឧត្តមសេនីយ៍ត្រី	គីម	ចាន់នី	ប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ
៣- លោកឧត្តមសេនីយ៍ត្រី	ប្រុក	សារឿន	ប្រធានលេខាធិការដ្ឋានក្រុមអ្នកច្បាប់
៤- លោកវរសេនីយ៍ឯក	សោម	សុភា	អនុប្រធានទី១ លេខាធិការដ្ឋាន
៥- លោកវរសេនីយ៍ឯក	ជុក	គីមហួ	អនុប្រធានទី១ នាយកដ្ឋានពត៌មានទូទៅ
៦- លោកវរសេនីយ៍ឯក	អៀង	សាមីន	អនុប្រធានទី១ នាយកដ្ឋានបំភ័ន្តអក្សរ
៧- លោកវរសេនីយ៍ឯក	គីម	សារេន	អនុប្រធានទី១ ការិយាល័យកណ្តាលនគរបាលអន្តរជាតិ
៨- លោកវរសេនីយ៍ឯក	ហ៊ឹម	ជុន	អនុប្រធានលេខាធិការដ្ឋាន
៩- លោកវរសេនីយ៍ឯក	យ៉េត	វិបញ្ញាក់	អនុប្រធានលេខាធិការដ្ឋាន

១០ - លោកវរសេនីយ៍ឯក ភួង ម៉ាល័យ អនុប្រធានសេនាធិការដ្ឋាន

១១ - លោកវរសេនីយ៍ឯក ឆាយ គីមខឿន អនុប្រធានសេនាធិការដ្ឋាន

១២ - លោកវរសេនីយ៍ឯក ម៉ៅ និម្មល ប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ

១៣ - លោកវរសេនីយ៍ឯក ឡាច យឺន ប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលនគរបាលព្រំដែន

១៤ - លោកវរសេនីយ៍ឯក គង់ ចន្ទី ប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលមធ្យោបាយ

១៥ - លោកវរសេនីយ៍ឯក ប៉ុក សុខន អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយអប់រំ

១៦ - លោកវរសេនីយ៍ឯក ប្រាក់ កាណារ៉ា អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក

១៧ - លោកវរសេនីយ៍ឯក ចេង សុវណ្ណ អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក

១៨ - លោកវរសេនីយ៍ឯក ហ៊ូ សេងលន់ អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក

១៩ - លោកវរសេនីយ៍ឯក ចៅង សំអាត អនុប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ

២០ - លោកវរសេនីយ៍ឯក ច័ន្ទ សុវណ្ណ អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

២១ - លោកវរសេនីយ៍ឯក ទូច ង៉ិម អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

២២ - លោកវរសេនីយ៍ឯក ធាម ប៊ុនសេង អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គីភ័យ

២៣ - លោកវរសេនីយ៍ឯក ខៀវ សុធា អនុប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម

២៤ - លោកវរសេនីយ៍ឯក តុល គីមលី អនុប្រធាននាយកដ្ឋានស្ថាបនា

២៥ - លោកវរសេនីយ៍ឯក អ៊ុម ម៉ុង អនុប្រធាននាយកដ្ឋានស្ថាបនា

២៦ - លោកវរសេនីយ៍ឯក ម៉ៃ ស៊ីវ អនុប្រធាននាយកដ្ឋានស្ថាបនា

២៧ - លោកវរសេនីយ៍ឯក ប៉ែម ម៉ៅ អនុប្រធាននាយកដ្ឋានបំភ័ន្តអក្សរ

២៨ - លោកវរសេនីយ៍ឯក ឡុង វិចិត្រ អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន

២៩ - លោកវរសេនីយ៍ឯក ជោត សំរ៉ាង អនុប្រធានលេខាធិការដ្ឋានក្រុមអ្នកច្បាប់

៣០ - លោកវរសេនីយ៍ឯក ឡាំ ប៊ុនថារ អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ

៣១ - លោកវរសេនីយ៍ឯក អ៊ិន សារិន អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ

៣២ - លោកវរសេនីយ៍ឯក កែវ វណ្ណថន អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ

៣៣ - លោកវរសេនីយ៍ឯក ពេជ្រ តុង អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ

៣៤ - លោកវរសេនីយ៍ឯក សំ បូរ អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ

៣៥ - លោកវរសេនីយ៍ឯក ឡុង លឹម ស្នងការនគរបាលខេត្តស្ទឹងត្រែង

៣៦ - លោកវរសេនីយ៍ទោ ហាវ ចាន់សិទ្ធី នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក

៣៧ - លោកវរសេនីយ៍ទោ វ៉ាន់ សារិទ្ធ នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក

៣៨ - លោកវរសេនីយ៍ទោ ខៀវ ចាន់រ៉ា ជំនួយការប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌

៣៩ - លោកវរសេនីយ៍ទោ ជីវ ផល្លី ជំនួយការប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌

៤០ - លោកវរសេនីយ៍ទោ ឃុត សុធា ជំនួយការប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ

៤១ - លោកវរសេនីយ៍ទោ	ជា	យឿន	ជំនួយការប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ
៤២ - លោកវរសេនីយ៍ទោ	ហេង	រត្តសីមា	នាយការិយាល័យ នៃលេខាធិការដ្ឋានក្រុមអ្នកច្បាប់
៤៣ - លោកវរសេនីយ៍ទោ	ហាក់	គីមរ៉ុង	នាយការិយាល័យ នៃការិយាល័យកណ្តាលនគរបាលអន្តរជាតិ
៤៤ - លោកវរសេនីយ៍ទោ	រស់	សុខា	នាយការិយាល័យ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
៤៥ - លោកវរសេនីយ៍ទោ	មុំ	ទិត្យសុផាន	នាយការិយាល័យ នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ
៤៦ - លោកវរសេនីយ៍ទោ	ងួន	គឿន	ស្នងការរងទី១ នគរបាលខេត្តស្ទឹងត្រែង
៤៧ - លោកវរសេនីយ៍ត្រី	នង	សារិន	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៤៨ - លោកវរសេនីយ៍ត្រី	ឈឹម	វ៉ានី	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៤៩ - លោកវរសេនីយ៍ត្រី	ប៊ុង	បូរ៉ា	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៥០ - លោកវរសេនីយ៍ត្រី	ស្មាន់	សារឿន	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៥១ - លោកវរសេនីយ៍ត្រី	ឱ	សំណាង	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៥២ - លោកវរសេនីយ៍ត្រី	សួរ	វេងលាង	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៥៣ - លោកវរសេនីយ៍ត្រី	ម៉ៅ	វ៉ាន់ដា	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៥៤ - លោកវរសេនីយ៍ត្រី	លាង	សេងហាន	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៥៥ - លោកវរសេនីយ៍ត្រី	អៀម	បូណារ័ត្ន	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៥៦ - លោកវរសេនីយ៍ត្រី	ឈឹម	ផន	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៥៧ - លោកវរសេនីយ៍ត្រី	ចាន់	សុខហេង	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៥៨ - លោកវរសេនីយ៍ត្រី	កែ	ខាន់ណារ៉ា	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៥៩ - លោកវរសេនីយ៍ត្រី	ឡុង	សុគន្ធ	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៦០ - លោកវរសេនីយ៍ត្រី	មាស	ចាន់ថន	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៦១ - លោកវរសេនីយ៍ត្រី	ឯម	សារិទ្ធ	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៦២ - លោកវរសេនីយ៍ត្រី	លន	ណាឡោម	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៦៣ - លោកវរសេនីយ៍ត្រី	កែវ	ហួរ	នាយរងការិយាល័យកណ្តាល នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៦៤ - លោកវរសេនីយ៍ត្រី	ង៉ែត	សូគីម	នាយរងការិយាល័យ នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ
៦៥ - លោកវរសេនីយ៍ត្រី	ស្រី	សុខា	នាយរងការិយាល័យ នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ
៦៦ - លោកវរសេនីយ៍ត្រី	គួន	សុគន្ធ	នាយរងការិយាល័យ នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ
៦៧ - លោកវរសេនីយ៍ត្រី	អេង	វុទ្ធី	នាយរងការិយាល័យ នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ
៦៨ - លោកវរសេនីយ៍ត្រី	ធុច	ខេមរិន្ទ	អនុប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលនគរបាលព្រំដែន
៦៩ - លោកវរសេនីយ៍ត្រី	ចាន់	បូរ៉ាន់	ជំនួយការប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន
៧០ - លោកវរសេនីយ៍ត្រី	លឹម	វណ្ណធី	ជំនួយការប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន
៧១ - លោកអនុសេនីយ៍ឯក	ណុប	សុផល	នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

ក / មេដាយប្រាក់ការងារ ចំនួន ១០០ រូប

១ -	លោកវរសេនីយ៍ឯក	គីម	ង៉ែតសុពល	អនុប្រធាននាយកដ្ឋានបំភ័ន្តអក្ខរ:
២ -	លោកវរសេនីយ៍ឯក	ឌុច	ឌឿន	អនុប្រធាននាយកដ្ឋានបំភ័ន្តអក្ខរ:
៣ -	លោកវរសេនីយ៍ទោ	តាន់	ប៉េងល្យេង	ជំនួយការប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ
៤ -	លោកវរសេនីយ៍ទោ	គីម	សាម៉ន	អនុប្រធានអង្គភាព នៃសេនាធិការដ្ឋាន
៥ -	លោកវរសេនីយ៍ទោ	ង៉ិល	វណ្ណធឿន	នាយការិយាល័យ នៃសេនាធិការដ្ឋាន
៦ -	លោកវរសេនីយ៍ទោ	គិន	ឡាយ	នាយការិយាល័យ នៃសេនាធិការដ្ឋាន
៧ -	លោកវរសេនីយ៍ទោ	ឃី	សាមឿន	នាយការិយាល័យ នៃសេនាធិការដ្ឋាន
៨ -	លោកវរសេនីយ៍ទោ	យុង	សំខាន់	នាយការិយាល័យ នៃសេនាធិការដ្ឋាន
៩ -	លោកវរសេនីយ៍ទោ	ហេង	សៀម	នាយការិយាល័យ នៃការិយាល័យកណ្តាលនគរបាលអន្តរជាតិ
១០ -	លោកវរសេនីយ៍ទោ	ជា	សុវណ្ណសុខ	នាយការិយាល័យ នៃការិយាល័យកណ្តាលនគរបាលអន្តរជាតិ
១១ -	លោកវរសេនីយ៍ទោ	យិន	យឿន	នាយការិយាល័យ នៃនាយកដ្ឋានបំភ័ន្តអក្ខរ:
១២ -	លោកវរសេនីយ៍ទោ	ខួង	គីមសាន្ត	នាយការិយាល័យ នៃនាយកដ្ឋានបំភ័ន្តអក្ខរ:
១៣ -	លោកវរសេនីយ៍ទោ	នូ	សារ៉ារិទ្ធ	នាយការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គិភ័យ
១៤ -	លោកវរសេនីយ៍ទោ	ស៊ុន	រ៉ូ	នាយការិយាល័យ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
១៥ -	លោកវរសេនីយ៍ទោ	ចេង	គីមហេង	នាយការិយាល័យ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
១៦ -	លោកវរសេនីយ៍ទោ	ព្រុំ	វុត្ថា	នាយការិយាល័យ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
១៧ -	លោកវរសេនីយ៍ទោ	កែប	សារឿន	នាយការិយាល័យ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
១៨ -	លោកវរសេនីយ៍ទោ	ហង្ស	សុផាណារ៉ា	នាយការិយាល័យ នៃនាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ
១៩ -	លោកវរសេនីយ៍ត្រី	យិន	តា	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
២០ -	លោកវរសេនីយ៍ត្រី	ភេម	កុង	អនុប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ
២១ -	លោកវរសេនីយ៍ត្រី	មុំល	រិទ្ធិ	អនុប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ
២២ -	លោកវរសេនីយ៍ត្រី	ហេង	សុវត្ថិ	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
២៣ -	លោកវរសេនីយ៍ត្រី	វ៉ាន់	ឡាយ	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
២៤ -	លោកវរសេនីយ៍ត្រី	ប្រុក	ម៉ៃឧត្តម	នាយរងការិយាល័យ នៃលេខាធិការដ្ឋានក្រុមអ្នកច្បាប់
២៥ -	លោកវរសេនីយ៍ត្រី	រស់	សាផល	នាយរងការិយាល័យ នៃលេខាធិការដ្ឋានក្រុមអ្នកច្បាប់
២៦ -	លោកវរសេនីយ៍ត្រី	ប្រាក់	ពៅ	នាយរងការិយាល័យ នៃលេខាធិការដ្ឋានក្រុមអ្នកច្បាប់
២៧ -	លោកវរសេនីយ៍ត្រី	ជឹម	ថា	នាយរងការិយាល័យ នៃលេខាធិការដ្ឋានក្រុមអ្នកច្បាប់
២៨ -	លោកវរសេនីយ៍ត្រី	ភួង	សុភី	នាយរងការិយាល័យ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
២៩ -	លោកវរសេនីយ៍ត្រី	យ៉យ	ឈួន	នាយរងការិយាល័យ នៃនាយកដ្ឋានសណ្តាប់ធ្នាប់

៣០ - លោកវរសេនីយ៍ត្រី អ៊ុក គឹមកាម៉ារ៉ាដ នាយរងការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គិភ័យ

៣១ - លោកវរសេនីយ៍ត្រី ប៉ាង ណារិទ្ធ នាយរងការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គិភ័យ

៣២ - លោកវរសេនីយ៍ត្រី យ៉ុន យ៉េ នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ

៣៣ - លោកវរសេនីយ៍ត្រី កែ សារ៉ុត នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ

៣៤ - លោកវរសេនីយ៍ត្រី ហ៊ុន លឹមហាក់ នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ

៣៥ - លោកវរសេនីយ៍ត្រី គង់ តៃស៊ុម នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង

៣៦ - លោកវរសេនីយ៍ត្រី ព្រែក សុខន នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង

៣៧ - លោកវរសេនីយ៍ត្រី បេង ដាណារ៉ា នាយរងការិយាល័យកណ្ដាល នៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង

៣៨ - លោកអនុសេនីយ៍ឯក សំ សារិទ្ធ នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

៣៩ - លោកអនុសេនីយ៍ឯក ដូ សុគឹម នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

៤០ - លោកអនុសេនីយ៍ឯក ហ៊ុល សម្បត្តិ នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

៤១ - លោកអនុសេនីយ៍ឯក ទេព ស៊ីន នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

៤២ - លោកអនុសេនីយ៍ឯក ពៅ សារឿន នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

៤៣ - លោកអនុសេនីយ៍ឯក លី នីន នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

៤៤ - លោកអនុសេនីយ៍ឯក សូ បារាំង នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

៤៥ - លោកអនុសេនីយ៍ឯក អ៊ុក ញ៉ាន នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

៤៦ - លោកអនុសេនីយ៍ឯក ហ៊ាន លី នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

៤៧ - លោកអនុសេនីយ៍ឯក ផាន់ ម៉ុង នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

៤៨ - លោកអនុសេនីយ៍ឯក ប្រាក់ សុផានិត នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

៤៩ - លោកអនុសេនីយ៍ឯក គង់ សម្បត្តិ នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក

៥០ - លោកអនុសេនីយ៍ឯក ឃួន មណ្ឌល មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក

៥១ - លោកអនុសេនីយ៍ឯក សេក វណ្ណា មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក

៥២ - លោកអនុសេនីយ៍ឯក ទូច ពលៈ មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក

៥៣ - លោកអនុសេនីយ៍ឯក ស៊ុន គឹមស៊ា មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក

៥៤ - លោកអនុសេនីយ៍ឯក យូ រី មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក

៥៥ លោកអនុសេនីយ៍ឯក ស៊ិន ដារ៉ូ មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក

៥៦ លោកអនុសេនីយ៍ឯក អឿ ខេង មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក

៥៧ - លោកអនុសេនីយ៍ឯក អៀវ ប៊ុនឡេង នាយផ្នែក នៃនាយកដ្ឋានកណ្ដាលនគរបាលយុត្តធម៌

៥៨ - លោកអនុសេនីយ៍ឯក លន់ រី នាយផ្នែក នៃលេខាធិការដ្ឋានក្រុមអ្នកច្បាប់

៥៩ - លោកអនុសេនីយ៍ឯក ជា ណាង នាយផ្នែក នៃនាយកដ្ឋានកណ្ដាលនគរបាលព្រំដែន

៦០ - លោកអនុសេនីយ៍ឯក វ៉ាន់ ចាវុធ នាយផ្នែក នៃនាយកដ្ឋានកណ្ដាលនគរបាលព្រំដែន

៦១ - លោកស្រីអនុសេនីយ៍ឯក ប៉ា សំភារី នាយផ្នែក នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ
៦២ - លោកអនុសេនីយ៍ឯក ឡាក់ ម៉ុន នាយផ្នែក នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ
៦៣ - លោកអនុសេនីយ៍ឯក ឡឹក សុធា នាយផ្នែក នៃនាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ
៦៤ - លោកអនុសេនីយ៍ឯក ទៀង សុផានី នាយផ្នែក នៃនាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ
៦៥ - លោកអនុសេនីយ៍ឯក ប៊ុក សាខុន នាយផ្នែក នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ
៦៦ - លោកស្រីអនុសេនីយ៍ឯក ទេព ធីតា នាយផ្នែក នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ
៦៧ - លោកអនុសេនីយ៍ឯក ពត ចាន់នី នាយផ្នែក នៃនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គីភ័យ
៦៨ - លោកអនុសេនីយ៍ឯក ស៊ុំ ប៊ុនថាំ អធិការនគរបាលស្រុកសន្ទុក នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៦៩ - លោកអនុសេនីយ៍ឯក នូ ថានី នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៧០ - លោកអនុសេនីយ៍ឯក ស្រី ស្រៀង នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៧១ - លោកអនុសេនីយ៍ឯក គង្គ ចាន់ទី នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៧២ - លោកអនុសេនីយ៍ឯក សៅ សុខា នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៧៣ - លោកអនុសេនីយ៍ទោ នួន ណាល់ នាយរងផ្នែក នៃនាយកដ្ឋានបុគ្គលិក
៧៤ - លោកអនុសេនីយ៍ទោ ហាន ទ្រង់ នាយរងផ្នែក នៃនាយកដ្ឋានបុគ្គលិក
៧៥ - លោកអនុសេនីយ៍ទោ វង្ស ផល្លា នាយរងផ្នែក នៃនាយកដ្ឋានបុគ្គលិក
៧៦ - លោកអនុសេនីយ៍ទោ ហេង ហ៊ុន នាយរងផ្នែក នៃនាយកដ្ឋានបុគ្គលិក
៧៧ - លោកស្រីអនុសេនីយ៍ទោ សោម ភារុណ នាយផ្នែក នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ
៧៨ - លោកស្រីអនុសេនីយ៍ទោ ឡឹក ស៊ីថា នាយផ្នែក នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ
៧៩ - លោកអនុសេនីយ៍ទោ សារី សម្បត្តិ នាយរងផ្នែក នៃនាយកដ្ឋានកណ្តាលនគរបាលយុត្តធម៌
៨០ - លោកអនុសេនីយ៍ទោ គី វណ្ណៈ នាយរងផ្នែក នៃសេនាធិការដ្ឋាន
៨១ - លោកអនុសេនីយ៍ទោ ឃួន សុជាតិ នាយរងផ្នែក នៃមន្ទីរប្រឆាំងគ្រឿងញៀន
៨២ - លោកអនុសេនីយ៍ទោ ឡេវ មុន្នី នាយរងផ្នែក នៃនាយកដ្ឋានកណ្តាលនគរបាលព្រំដែន
៨៣ - លោកអនុសេនីយ៍ទោ ហួត ហៃ នាយរងផ្នែក នៃនាយកដ្ឋានកណ្តាលនគរបាលព្រំដែន
៨៤ - លោកស្រីអនុសេនីយ៍ទោ ឈឹម យ៉ាដាមុនី នាយរងផ្នែក នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ
៨៥ - លោកអនុសេនីយ៍ទោ ជិន សុផល នាយរងផ្នែក នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ
៨៦ - លោកអនុសេនីយ៍ទោ ម៉ម ប៊ុន នាយរងផ្នែក នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ
៨៧ - លោកអនុសេនីយ៍ទោ ញ៉ៀម ឈុនលី អធិការរងនគរបាលស្រុកបារាយណ៍ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៨៨ - លោកអនុសេនីយ៍ទោ ឯក វរៈ នាយរងផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៨៩ - លោកអនុសេនីយ៍ទោ ពេជ ចាល់ នាយរងផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៩០ - លោកអនុសេនីយ៍ទោ សន តាល់ នាយរងផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
៩១ - លោកអនុសេនីយ៍ត្រី មុយ ជន នាយផ្នែក អធិការដ្ឋាន ន.ប ស្រុកអូរជ្រៅ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ

៩២ - លោកអនុសេនីយ៍ត្រី	ជា	ដួង	មន្ត្រី នៃនាយកដ្ឋានកណ្តាលនគរបាលព្រំដែន
៩៣ លោកអនុសេនីយ៍ត្រី	យន	សារ៉ាត់	នាយប៉ុស្តិ៍ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
៩៤ - លោកអនុសេនីយ៍ត្រី	ឯក	ចាន់ប៊ូលី	នាយផ្នែកចំណុះវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
៩៥ - លោកអនុសេនីយ៍ត្រី	ហេង	ខេមរា	នាយផ្នែកចំណុះវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
៩៦ - លោកអនុសេនីយ៍ត្រី	លី	ម៉ាឡៃ	នាយផ្នែកចំណុះវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
៩៧ - លោកព្រិន្ទបាលឯក	សេង	សំអុន	នាយរងផ្នែកចំណុះវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
៩៨ - លោកព្រិន្ទបាលឯក	ម៉េញ	សាម៉េត	នាយរងផ្នែកចំណុះវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
៩៩ - លោកព្រិន្ទបាលឯក	ព្រហ្ម	ឫទ្ធី	នាយរងផ្នែកចំណុះវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
១០០ - លោកពលបាលត្រី	នូ	ទិន	មន្ត្រី នៃនាយកដ្ឋានបុគ្គលិក

ក / មេដាយសេវិន្ទ្ធការងារ ចំនួន ២១ រូប

១ - លោកវរសេនីយ៍ទោ	សុខ	ឡុន	នាយការិយាល័យ នៃនាយកដ្ឋានបំភ័ន្តអក្ខរៈ
២ - លោកវរសេនីយ៍ត្រី	អ៊ូច	សារឿន	នាយរងការិយាល័យ នៃនាយកដ្ឋានបំភ័ន្តអក្ខរៈ
៣ - លោកវរសេនីយ៍ត្រី	នាក់	សំផល	នាយរងការិយាល័យ នៃនាយកដ្ឋានបំភ័ន្តអក្ខរៈ
៤ - លោកវរសេនីយ៍ត្រី	ទិន	ទី	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
៥ - លោកវរសេនីយ៍ត្រី	សេក	ប៊ូ	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
៦ - លោកវរសេនីយ៍ត្រី	លឹម	សុខារស្មី	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
៧ - លោកវរសេនីយ៍ត្រី	ឈន	រ៉ូរ	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
៨ - លោកវរសេនីយ៍ត្រី	ព្រហ្ម	ចារិទ្ធ	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
៩ - លោកវរសេនីយ៍ត្រី	សំ	ម៉ារឌី	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
១០ - លោកវរសេនីយ៍ត្រី	ជិន	ស៊ីវុធ	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
១១ - លោកវរសេនីយ៍ត្រី	កែវ	ណាលីន	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
១២ - លោកវរសេនីយ៍ត្រី	អែម	សារិន	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
១៣ - លោកវរសេនីយ៍ត្រី	ស៊ិន	សៀក	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
១៤ - លោកវរសេនីយ៍ត្រី	លាង	សុវណ្ណ	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
១៥ - លោកវរសេនីយ៍ត្រី	ម៉ី	សុផល	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
១៦ - លោកវរសេនីយ៍ត្រី	កៅ	ស័រ	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
១៧ - លោកវរសេនីយ៍ត្រី	សរ	សារ៉ាត	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
១៨ - លោកវរសេនីយ៍ត្រី	ញឹម	ឡាយ	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍
១៩ - លោកវរសេនីយ៍ត្រី	ស៊ង់	ណារិន	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍

២០ - លោកវរសេនីយ៍ត្រី ម៉ិត្ត យង់ នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលទេសចរណ៍

២១ - លោកអនុសេនីយ៍ឯក ញ៉ុង ពេញ នាយផ្នែក នៃនាយកដ្ឋានបំភ័ន្តអក្ខរៈ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចក្នុងមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច* ✓
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៤៨៣...អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ស ម្រេ ច

មាត្រា ១.-

តែងតាំងលោក **សេង សាខន** ជាប្រធាននាយកដ្ឋានពត៌មាន និង សារគមនាគមន៍ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវ អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] តុលា ឆ្នាំ ២០០៤

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៥០ អនក្រ-បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា ១. -

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ចំនួន ០២ គ្រឿង ជូនអ្នកបច្ចេកទេសបារាំង ចំនួន ០២ រូប ដែលបានចូលរួមវិភាគទានថវិកាចំនួន ៤២៧.៤០០ ដុល្លារអាមេរិក សំរាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងមន្ទីរពេទ្យ **ព្រះបាទនរោត្តម សីហនុ** ចាប់តាំងពីឆ្នាំ ២០០១ រហូតមកដល់បច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម ៖

១-លោកសាស្ត្រាចារ្យ **Simon SCHRAUB Président Cancérologue Sans Frontières**
២-លោក **Daniel TAISANT Président Physicien Médical Sans Frontières**

មាត្រា ២. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ XtN

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ [illegible] ឆ្នាំ ២០០៤

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៥១...អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស / រកម /០៧០៤ /០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ.
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អាជ្ញាធរជាតិប្រយុទ្ធ នឹង ជំងឺអេដស៍

ស ម្រេ ច

មាត្រា ១. -

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោក **Jack N. Spencer** ប្រធានអង្គការប្រយុទ្ធ នឹង ជំងឺឆ្លងសហរដ្ឋអាមេរិក-កម្មវិធីបង្ការ និង ការពារជំងឺអេដស៍ជាសកលនៅកម្ពុជា (USCDC) ដែលបានជួយឧបត្ថម្ភ និង គាំទ្រ ក្នុងការបង្កើនសមត្ថភាពការងារដល់ក្រសួងសុខាភិបាល ជាពិសេសមជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹង ជំងឺអេដស៍ សើស្បែក និង កាមរោគធ្វើអោយសេវាបង្ការ និង ថែទាំអ្នកផ្ទុកមេរោគអេដស៍ និង អ្នកជំងឺអេដស៍កម្ពុជា មានគុណភាពខ្ពស់ ។

មាត្រា ២. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អាជ្ញាធរជាតិប្រយុទ្ធ នឹង ជំងឺអេដស៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/ ៚

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ... ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៥២ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១. ~

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោកស្រី ***Rebecca Marry Skotte Hansen*** តំណាងអង្គការកម្មវិធីស្បៀងអាហារពិភពលោក (***WFP***) ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការតស៊ូស្វែងរកជំនួយសំរាប់ជួយអភិវឌ្ឍន៍ និង កាត់បន្ថយភាពក្រីក្រ នៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២. ~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ... ខែ ១៧ . ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>**អ្នកទទួល :**</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

A..107

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៥៣ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

~~~~~~~~~~~~~

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១ .-

ត្រូវបានតែងតាំងមន្ត្រីរាជការ នៅខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានរាយនាមដូចខាងក្រោម :

- ឯកឧត្តម **អ៊ុំ ខេង** នាយកខុទ្ទកាល័យ បន្ថែមលើមុខងារបច្ចុប្បន្ន
- លោក **សេង សត្ថា** នាយករងខុទ្ទកាល័យ មានឋានៈស្មើអគ្គនាយករង
- លោក **ឡៀប សារីវិសិដ្ឋ** នាយករងខុទ្ទកាល័យ មានឋានៈស្មើអគ្គនាយករង

មាត្រា ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ១៧ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

01-10-04 S.&.S
~~~~~~~~~~~~~

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៤៤.អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

សម្រេច

មាត្រា១. ~

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក *Seong Jun BAE , Team Leader of KOREA Consultants International (KCI)* ដែលមានស្នាដៃល្អក្នុងការរួមចំណែកសិក្សា និង រៀបចំគម្រោងប្លង់លើកំណាត់ផ្លូវជាតិលេខ៣ ពីទីរួមខេត្តកំពត ដល់ត្រពាំងរពៅ ។

មាត្រា២. ~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ១៧ ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច /
-ឯកសារ-កាលប្បវត្តិ

A.109

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៣ ស.សរ

សេចក្តីសម្រេច

ស្តីពី

ការប្រគល់ភារកិច្ចជាសមាជិកក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងជាប្រធានអង្គភាពសំរបសំរួលអចិន្ត្រៃយ៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១៥២ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១.-

ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **ស៊ុំ ម៉ានិត** ទីប្រឹក្សារាជរដ្ឋាភិបាល ជាសមាជិកក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងជាប្រធានអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែ ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

ប្រការ ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងឯកឧត្តម **ស៊ុំ ម៉ានិត** ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤ សសរ

សេចក្តីសំរេច
ស្តីពី
ការអនុញ្ញាតអោយមន្ត្រីរាជការលាឈប់ពីមុខតំណែង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៤/០៥៩ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការផ្លាស់ប្តូរ តែងតាំង និងបែងចែកភារកិច្ចជូនឯកអគ្គរាជទូតប្រចាំនៅបរទេស
- បានឃើញសេចក្តីសំរេចលេខ ៣៩ សសរ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មការជាតិយូណេស្កូកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ៧៥ សសរ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការបន្ថែមសមាសភាពនៃគណៈកម្មការជាតិយូណេស្កូកម្ពុជា
- យោងតាមសំណើរបស់ប្រធានគណៈកម្មការជាតិយូណេស្កូកម្ពុជា

ស ម្រេ ច

ប្រការ១ .-

ត្រូវបានអនុញ្ញាតជូនលោកជំទាវ **ស៊ុន សារត៊ីន** លាឈប់ពីមុខតំណែង **អនុប្រធាន** នៃគណៈកម្មការជាតិយូណេស្កូកម្ពុជា ។

ប្រការ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការជាតិយូណេស្កូកម្ពុជា ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ[illegible] ឆ្នាំ២០០៤

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៥ សសរ

សេចក្តីសម្រេច
ស្តីពីការចាត់តាំងគណៈកម្មការរៀបចំព្រះរាជពិធីអភិសេក ថ្វាយព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី

រាជរដ្ឋាភិបាលកម្ពុជា

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០៣ ចុះថ្ងៃទិ ១១ ខែតុលាឆ្នាំ ២០០៤ ប្រកាស អោយច្បាប់ ស្តីពីការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ
- បានឃើញសេចក្តីសម្រេច លេខ ករស/សសរ/១០០៤/០០១ របស់ក្រុមប្រឹក្សារាជសម្បត្តិ ស្តីពីការជ្រើសរើសសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ជាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការងារចាំបាច់

សម្រេច

ប្រការ ១.- បង្កើតគណៈកម្មការមួយទទួលបន្ទុករៀបចំព្រះរាជពិធីអភិសេក ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដូចមានសមាសភាពខាងក្រោមនេះ :

១- សម្តេច ចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីធ្លារ គង់ សំអុល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីព្រះបរមរាជវាំង និងជាប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ		ប្រធាន
២- ឯកឧត្តម ម៉ិន ឃិន	អនុប្រធានអចិន្ត្រៃយ៍ គ.ប.ជ.អ និងជារដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា	អនុប្រធានអចិន្ត្រៃយ៍
៣- ឯកឧត្តម ហ៊ីម ឆែម	រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	សមាជិក
៤- អ្នកឧកញ៉ា ព្រះស្តេចធិបតី ខិន ព្រហ្ម	ផ្នែកធម្មការព្រះបរមរាជវាំង	សមាជិក
៥- ឧកញ៉ា សុធម្មប្រីជា នូ ចាន់	ផ្នែកធម្មការព្រះបរមរាជវាំង	សមាជិក
៦- អ្នកឧកញ៉ា ភក្តីព្រះស្តេច ហេង គីមគុណ	ផ្នែកធម្មការព្រះបរមរាជវាំង	សមាជិក

៧- ព្រះជយាធិបតី គង់ គេន	ប្រធានផ្ទៃកបារគូ	សមាជិក
៨- ឯកឧត្តម អ៊ុក រ៉ាប៊ុន	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៩- ឯកឧត្តម ខាង់ ផែន	រដ្ឋលេខាធិការក្រសួងព័ត៌មាន	សមាជិក
១០- ឯកឧត្តម ឡុង វិសាលោ	រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
១១- ឯកឧត្តម ហុក ឡុងឌី	អគ្គស្នងការនគរបាលជាតិ	សមាជិក
១២- ឯកឧត្តម សៅ សុខា	មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
១៣- ឯកឧត្តម យូ ស៊ុនឡុង	អគ្គស្នងការនគរបាលជាតិ	សមាជិក
១៤- ឯកឧត្តម កែប ជុតិមា	អភិបាលរាជធានីភ្នំពេញ	សមាជិក
១៥- ឯកឧត្តម គុយ សុផល	រដ្ឋលេខាធិការព្រះបរមរាជវាំង	សមាជិក
១៦- ឯកឧត្តម ជុំ ឡើន	រដ្ឋលេខាធិការព្រះបរមរាជវាំង	សមាជិក
១៧- ឯកឧត្តម ជា សុខុម	អគ្គលេខាធិការរងទី១ គ.ប.ជ.អ	សមាជិក
១៨- ឯកឧត្តម ឈា ហន	អនុរដ្ឋលេខាធិការព្រះបរមរាជវាំង	សមាជិក
១៩- ឯកឧត្តម ជា គាន	អគ្គលេខាធិការរង នៃ គ.ប.ជ.អ	សមាជិក
២០- ឯកឧត្តម ញៀម ទាវលី	អគ្គលេខាធិការរង នៃ គ.ប.ជ.អ	សមាជិក
២១- ឯកឧត្តម សូ ស៊ីខួន	អនុរដ្ឋលេខាធិការព្រះបរមរាជវាំង	សមាជិក
២២- ឯកឧត្តម ប៊ួន លីមហេង	ទីប្រឹក្សាទីស្តីអមការគណៈរដ្ឋមន្ត្រី	សមាជិក
២៣- ឯកឧត្តម រស់ គង់	អគ្គលេខាធិការរង នៃ គ.ប.ជ.អ	សមាជិក
២៤- ឯកឧត្តម គន់ យ៉ាន	អគ្គនាយកវិទ្យុជាតិកម្ពុជា	សមាជិក
២៥- ឯកឧត្តម ឈិន កេតនា	អគ្គលេខាធិការរង នៃ គ.ប.ជ.អ	សមាជិក
២៦- ឯកឧត្តម គីម គុណាវឌ្ឍន៍	អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា	សមាជិក
២៧- ឯកឧត្តម សួន ឈាងលី	ប្រធាននាយកដ្ឋានអង្គរក្ស	សមាជិក
២៨- ឯកឧត្តម សេង សុង	មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ	សមាជិក
២៩- ឯកឧត្តម ហេង ពៅ	ស្នងការនគរបាលរាជធានីភ្នំពេញ	សមាជិក
៣០- លោក អ៊ាត ស៊ីលា	ប្រធាននាយកដ្ឋានពិធីការ គ.ប.ទ	សមាជិក

ប្រការ ២ .- គណៈកម្មការនេះមានភារកិច្ច :

- ទទួលបន្ទុករៀបចំព្រះរាជពិធីអភិសេក ព្រះមហាក្សត្រថ្មី ឱ្យបានប្រព្រឹត្តទៅស្របតាមព្រះរាជប្រពៃណី ជាតិ ប្រពៃណីព្រះពុទ្ធសាសនា.
- សិក្សាស្រាវជ្រាវឯកសារពាក់ព័ន្ធ រូបភាពចាត់តាំង ស្តីពីព្រះរាជពិធីអភិសេក.
- លើកគម្រោងរូបភាពចាត់តាំង ព្រះរាជពិធីអភិសេកឱ្យបានសក្តិសម.
- សាងសង់មហាបុស្បុកដ៏ល្អមួយ បំពាក់ក្បូរក្បាច់រចនាតាមរចនាបទខ្មែរ សម្រាប់ស្រង់ព្រះសុគន្ធវារី.

- យាង-អញ្ជើញ ព្រះរាជវង្សានុវង្ស ឧត្តមប្រឹក្សាព្រះមហាក្សត្រ ថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ឯកអគ្គរាជទូត-រដ្ឋទូត-ភារធារី ចូលរួម តាមចំនួនកំណត់.
- ធ្វើការផ្សព្វផ្សាយទូលាយតាមបណ្តាញឃោសនាជាតិ-អន្តរជាតិ អំពីព្រះរាជជីវប្រវត្តិព្រះមហាក្សត្រថ្មី និងឯកសារផ្សេងៗ តាមសំណូមពរចាំបាច់.
- រៀបចំព្រះរាជកកុធភ័ណ្ឌ មានព្រះភូសាជាយ-មកុដ-សុពណ៌បាទ-ព្រះរាជបល្ល័ង្ក-ព្រះសល្វេង-បុស្បុកទៀនជ័យ គ្រឿងហែរក្បួនគ្រប់មុខ ។
- ធ្វើព្រះរាជកម្មវិធីលំអិត សម្រាប់ដំណើរការងារក្នុងព្រះរាជពិធីអភិសេក.
- រក្សាការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់ ឱ្យបានល្អប្រសើរគ្រប់ទីកន្លែង.

ប្រការ ៣.- ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈដោះស្រាយ សម្ភារៈ ថវិកា បំរើការរៀបចំព្រះរាជពិធីរាជាភិសេក ឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ។

ប្រការ ៤.- គណៈកម្មការនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញមួយចំនួន ជាជំនួយការ តាមតម្រូវការចាំបាច់.

ប្រការ ៥.- គណៈកម្មការនេះ មានទីតាំងអចិន្ត្រៃយ៍ នៅអគ្គលេខាធិការដ្ឋានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ និងប្រើប្រាស់ត្រារបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ។

ប្រការ ៦.- ឯកឧត្តម ដូចមាននាមប្រការមួយ ត្រូវទទួលភារកិច្ចអនុវត្តតាមស្មារតី សេចក្តីសំរេចនេះ ឱ្យសម្រេចលទ្ធផលល្អប្រសើរ ។

ប្រការ ៧.- សេចក្តីសំរេចនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- ដូចក្នុងប្រការមួយ
  " ដើម្បីសហការអនុវត្តន៍ "
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No ២០៧ MOC / M 2004

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០៤

ប្រកាស

ស្តីពីការដាក់ឱ្យដេញថ្លៃ លើកទី ៤ នូវកូតា សម្លៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០០៤

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤/អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ១- គ្រប់រោងចក្រកាត់ដេរទាំងអស់ដែលកំពុងដំណើរការ និងដែលបានចុះបញ្ជី នៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម (នាយកដ្ឋាន GSP) នៃក្រសួងពាណិជ្ជកម្ម មុនថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ ត្រូវបានអញ្ជើញឱ្យមកចូលរួម ក្នុងការដេញថ្លៃលើកទី ៤ នូវកូតា **Quota** សម្លៀកបំពាក់សំរាប់នាំចេញទៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៤ ដោយយោលទៅលើលទ្ធភាពផលិតកម្មរបស់ខ្លួន ។

ប្រការ២- រោងចក្រនីមួយៗត្រូវបានអនុញ្ញាតឱ្យដេញថ្លៃ យកបរិមាណតិច ឬស្មើនឹងបរិមាណនៃ កូតា ដែលដាក់ ឱ្យដេញថ្លៃ តាមប្រភេទនីមួយៗនៃ **Quota** ដូចតទៅ :

ប្រភេទ	បរិមាណដេញថ្លៃ (ឡូតិ៍)	ប្រភេទ	បរិមាណដេញថ្លៃ (ឡូតិ៍)
៣៣៤/៦៣៤	៩.០៧១	៣៥២/៦៥២	៦៨.០៥០
៣៣៥/៦៣៥	៣៤៤	៤៣៥	១២.៥០៦
៣៣៨/៣៣៩	១៤.១៧០	៤៣៨	៣៥.៦៨៥
៣៤០/៦៤០	២៥៣.១៤១	៤៤៥/៤៤៦	៦១.៧០២
៣៤៥	៥១៩	៦៣៨/៦៣៩	១៤២.៨៣៣
៣៤៧/៣៤៨/៦៤៧/៦៤៨	១៥.៨៩១	៦៤៥/៦៤៦	១៨៥.៦០៣

ប្រការ៣- ពាក្យសុំដេញថ្លៃនីមួយៗ ត្រូវភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រដែលមានការបញ្ជាក់ពីធនាគារ (Certified Check)ដែលមានតំលៃស្មើនឹងតំលៃដេញថ្លៃសរុប ។ មូលប្បទានប័ត្រនេះ ត្រូវបានសរសេរឱ្យទូទាត់ប្រាក់ជូន គណកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ (Export Quotas Management Committee " EQMC ") ។ ការសរសេរបង់ប្រាក់មិនគ្រប់តាមចំនួននៃតម្លៃដេញថ្លៃសរុប នឹងនាំឱ្យពាក្យសុំដេញថ្លៃ ត្រូវបានចាត់ទុកជាអាសារបង់ ។

<u>ឧទាហរណ៍ រោងចក្រ A:</u>

ដេញថ្លៃ ចំនួន ២០ ០០០ ឡូតិ៍ តំលៃ ៨ ដុល្លា/ឡូតិ៍ = ១៦០.០០០ ដុល្លា

ទឹកប្រាក់ត្រូវសរសេរលើមូលប្បទានប័ត្រ គឺ = ១៦.០០០ ដុល្លា

ប្រការ៤- ការដេញថ្លៃក្នុងតំលៃខ្ពស់បំផុតតាម ប្រភេទ (Category) នឹងបានទទួលជ័យជំនះ ។ កូតា (Quota) នឹងត្រូវបានបែងចែកដល់អ្នកដេញថ្លៃ ដែលបានទទួលជោគជ័យ រហូតដល់ បរិមាណ Quota សរុប ត្រូវបានបែងចែកអស់ ។

ប្រការ៥- កូតា **(Quota)** ដែលសេសសល់ពីការដេញថ្លៃ នឹងត្រូវបានចាត់ចែង តាមសមត្ថកិច្ច របស់ ក្រសួងពាណិជ្ជកម្ម។

ប្រការ៦- តំលៃនៃការចូលរួមដេញថ្លៃ នឹងត្រូវទទួលយក ចំពោះរាល់ការបន្ថែមចំនួនទសភាគ ២០ សេន (ម្ភៃ) នៃប្រាក់ដុល្លាសហរដ្ឋអាមេរិកលើថ្លៃឯកត្តាតាមប្រភេទ នីមួយៗ :

ប្រភេទ	ថ្លៃដេញអប្បបរមា	ប្រភេទ	ថ្លៃដេញអប្បបរមា
Cat ៣៣៤/៦៣៤	3.00$/doz	Cat ៣៥២/៦៥២	0.10$/doz
Cat ៣៣៥/៦៣៥	10.00$/doz	Cat ៤៣៥	3.00$/doz
Cat ៣៣៨/៣៣៩	4.00$/doz	Cat ៤៣៨	1.00$/doz
Cat ៣៤០/៦៤០	0.50$/doz	Cat ៤៤៥/៤៤៦	5.00$/doz
Cat ៣៤៥	2.00$/doz	Cat ៦៣៨/៦៣៩	3.00$/doz
Cat ៣៤៧-៨/៦៤៧-៨	3.00$/doz	Cat ៦៤៥/៦៤៦	0.50$/doz

ប្រការ៧- ពាក្យដេញថ្លៃត្រូវដាក់ជូន ឯកឧត្តមប្រធានគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ " EQMC " នៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំង នៅជាន់ទី២ អាគារលេខ ២០ B មហាវិថីព្រះនរោត្តម ។

ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ភ្ជាប់ជាមួយនូវមូលប្បទានប័ត្របញ្ជាក់ពីធនាគារ ដាក់ក្នុងស្រោមសំបុត្រនោះផង ។

ប្រការ ៨- កាលបរិច្ឆេទនៃការបើកស្រោមសំបុត្រដេញថ្លៃ គឺនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៤ ចាប់ពីម៉ោង ៨:០០ ព្រឹក នៅទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាន់ទី២ អាគារលេខ ២០ អា មហាវិថីព្រះនរោត្តម ។

ប្រការ ៩- កាលបរិច្ឆេទឈប់ទទួលពាក្យដេញថ្លៃគឺនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ វេលាម៉ោង ៥:០០ ល្ងាច ។

ប្រការ ១០- លទ្ធផលនៃការដេញថ្លៃ នឹងត្រូវប្រកាសជាសាធារណៈ នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៤ តាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

ប្រការ ១១- អ្នកចូលរួមដេញថ្លៃ ដែលបានទទួលជោគជ័យ នឹងអាចប្រើប្រាស់កូតាបាន ចាប់ពីថ្ងៃទី ២៩ តុលា ២០០៤ តទៅ ។ កូតាដែលបានដេញថ្លៃហើយ ហើយមិនបានប្រើប្រាស់អស់នៅដំណាច់ឆ្នាំ ២០០៤ នឹងមិនត្រូវបានក្រសួងពាណិជ្ជកម្មទូទាត់តំលៃដេញថ្លៃសងវិញនោះទេ ។

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 (Kingdom of Cambodia)
Minister's Mobile Phone (855-12) 821888 Facsimile. (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396

ប្រការ ១២- អ្នកចូលរួមដេញថ្លៃដែលមិនបានទទួលជោគជ័យ នឹងត្រូវបានផ្តល់ជូនវិញនូវមូលប្បទានប័ត្រ របស់ខ្លួន ចាប់ពីថ្ងៃបន្ទាប់ពីថ្ងៃដេញថ្លៃតទៅ ។

ប្រការ ១៣- ការសំរេចរបស់ EQMC នៅក្នុងការអនុវត្តការដេញថ្លៃ ជាការសំរេចចុងក្រោយ ។

ប្រការ ១៤- អគ្គនាយកបច្ចេកទេស នាយិកាខុទ្ទកាល័យ ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និង សមាជិកគណកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រការនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

និងជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

<u>ចំលងជូនៈ</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

  " ដើម្បីជ្រាបជាពត៌មាន "

-ដូចប្រការ ១៤
- រាជកិច្ច /
- ទូរទស្សន៍ជាតិ វិទ្យុជាតិ និងសារពត៌មានជាតិ
- ឯកសារ កាលប្បវត្តិ

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 (Kingdom of Cambodia)
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones. (855-12) 933 323 / 881223 Facsimile: (855-23) 426396

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៣៣៦ ប្រក.កសក

ប្រកាស

ស្តីពី

ការបង្កើតតំបន់ប្រភពគ្រាប់ពូជឈើនាងនួន ឆ្លង់ សុក្រម បេង ពពេល និង គគីរថ្ម នៅក្នុងខេត្តរតនគីរី

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ អនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋាន រុក្ខា-ប្រមាញ់ ទៅជា រដ្ឋបាលព្រៃឈើ

- បានឃើញ ប្រកាសលេខ ៥០៩ ប្រក.កសក-បុ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ

- តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ

ស ម្រេ ច

ប្រការ១ : បង្កើតតំបន់ប្រភពគ្រាប់ពូជឈើចំនួន បួន(០៤)កន្លែងក្នុងខេត្តរតនគិរី ក្នុងគោលបំណងអភិរក្ស និង ធ្វើការសិក្សាលើលក្ខណៈសេនេទិក និង ប្រមូលគ្រាប់ពូជសម្រាប់ផ្គត់ផ្គង់ដល់តម្រូវការនៃកម្មវិធីដាំដើមឈើ និង ស្តារព្រៃឈើឡើងវិញ។

តំបន់ទី១: តំបន់ប្រភពគ្រាប់ពូជឈើនាងនួន (*Dalbergia bariensis* Pierre) ថ្នង់ (*Pterocarpus pedatus* Pierre) និង សុក្រម (*Xylia dolabriformis* Benth.) មានផ្ទៃដីទំហំម្ភៃមួយ (២១) ហិកតា ស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើវ៉ឺនសៃ ក្នុងភូមិសាស្រ្តឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី ដែលមានព្រំប្រទល់ដូចមានកំណត់ក្នុងផែនទីមាត្រដ្ឋាន ១ ៖ ២៥ ០០០ ភ្ជាប់ជាឧបសម្ព័ន្ធ និង មាននិយាមកា: ក (០៧ ០៦ ៩៣១; ១៥ ២០ ១៤៩), ខ (០៧ ០៦ ៦៨១; ១៥ ២០ ២១៥), គ (០៧ ០៦ ៤៧០; ១៥ ២០ ៤០៩), ឃ (០៧ ០៦ ២៣៤; ១៥ ២០ ៦៥០), ង (០៧ ០៦ ៩២៥; ១៥ ២០ ៦៤៣) ជាខ្សែព្រំប្រទល់បិទ។

តំបន់ទី២: តំបន់ប្រភពគ្រាប់ពូជឈើបេង (*Afzelia xylocarpa* (Kurz) Craib) នាងនួន (*Dalbergia bariensis* Pierre) និងពពេល (*Shorea cochinchinensis* Pierre) មានផ្ទៃដីទំហំម្ភៃ (២០) ហិកតា ស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើលំផាត់ ក្នុងភូមិសាស្រ្តភូមិឡាអ៊ិន ឃុំតឺន ស្រុកកូនមុំ ខេត្តរតនគិរី ដែលមានព្រំប្រទល់ដូចមានកំណត់ក្នុងផែនទីមាត្រដ្ឋាន ១ ៖ ២៥ ០០០ ភ្ជាប់ជាឧបសម្ព័ន្ធ និង មាននិយាមកា: ក (០៧ ០៤ ០០១; ១៥ ០៤ ៤៦៨), ខ (០៧ ០៤ ៥០៤; ១៥ ០៤ ៤៧១), គ (០៧ ០៤ ៥០៣; ១៥ ០៤ ០៨១), ឃ (០៧ ០៤ ០០៨; ១៥ ០៤ ០៦៣) ជាខ្សែព្រំប្រទល់បិទ។

តំបន់ទី៣: តំបន់ប្រភពគ្រាប់ពូជឈើគគីរថ្ម (*Hopea ferrea* Pierre)មានផ្ទៃដីទំហំសាមសិប(៣០) ហិកតា ស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើ លំផាត់ ក្នុងភូមិសាស្រ្តភូមិឡាអ៊ិន ឃុំតឺន ស្រុកកូនមុំ ខេត្តរតនគិរី ដែលមានព្រំប្រទល់ដូចមានកំណត់ក្នុងផែនទីមាត្រដ្ឋាន ១៖២៥ ០០០ ភ្ជាប់ជាឧបសម្ព័ន្ធនិងមាននិយាមកា: ក (០៧ ០៥ ១៣១; ១៥ ០៥ ៤០៣), ខ (០៧ ០៥ ៨៧០; ១៥ ០៥ ៤២៨), គ (០៧ ០៥ ៨៧៤; ១៥ ០៥ ០០០), ឃ (០៧ ០៥ ៣៥៧; ១៥ ០៥ ០០៥), ង (០៧ ០៥ ១៧៥; ១៥ ០៥ ០៤៦), ច (០៧ ០៥ ១៧៥; ១៥ ០៥ ១៩៧) ជាខ្សែព្រំប្រទល់បិទ។

តំបន់ទី៤: តំបន់ប្រភពគ្រាប់ពូជឈើបេង (*Afzelia xylocarpa* (Kurz) Craib) នាងនួន (*Dalbergia bariensis* Pierre) និង ថ្នង់ (*Pterocarpus pedatus* Kurz)មានផ្ទៃដីទំហំដប់ប្រាំបី (១៨) ហិកតា ស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើលំផាត់ ក្នុងភូមិសាស្រ្តឃុំយក្សឡោម ស្រុកបានលុង ខេត្តរតនគិរី ដែលមានព្រំប្រទល់ដូចមានកំណត់ក្នុងផែនទីមាត្រដ្ឋាន ១៖២៥០០០ ភ្ជាប់ជាឧបសម្ព័ន្ធ និងមាននិយាមកា: ក (០៧ ២១ ៦២៣; ១៥ ១៥ ៩០០), ខ (០៧ ២១ ៧៣៥; ១៥ ១៥ ៩៩៧), គ (០៧ ២១ ៧៥៩; ១៥

១៦ ០៤៣), ឃ (០៧ ២២ ២៥២; ១៥ ១៦ ០៤០), ង (០៧ ២២ ១៨៨; ១៥ ១៥ ៨៣៧), ច (០៧ ២២ ០៩៣; ១៥ ១៥ ៧៧៤), ឆ (០៧ ២២ ០២១; ១៥ ១៥ ៧៩៨), ជ (០៧ ២១ ៨៩៦; ១៥ ១៥ ៧២៦), ឈ (០៧ ២១ ៧៦១; ១៥ ១៥ ៦៥៥), ញ (០៧ ២១ ៦៩៩; ១៥ ១៥ ៦៨៤), ដ (០៧ ២១ ៦៤៩; ១៥ ១៥ ៧៤២) ជាខ្សែព្រំប្រទល់បិទ។

ប្រការ២ : តំបន់ប្រភពគ្រាប់ពូជឈើនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ រដ្ឋបាលព្រៃឈើ ដោយមានភារកិច្ចទទួលខុសត្រូវដូចតទៅ :

- រដ្ឋបាលព្រៃឈើថ្នាក់កណ្តាលមានភារកិច្ចសម្របសម្រួល សិក្សាស្រាវជ្រាវ ផ្សព្វផ្សាយ និង បណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រង ថែរក្សា និង ប្រមូលគ្រាប់ពូជឈើ នាងនួន ធ្នង់ សុក្រម បេង ពពេល និងគគីរថ្ម ក្នុងតំបន់នេះ
- ខណ្ឌរដ្ឋបាលព្រៃឈើរតនគីរី (ផ្នែករដ្ឋបាលព្រៃឈើវើនសៃ និង លំផាត់) មានភារកិច្ចគ្រប់គ្រង ថែរក្សា និង ប្រមូលគ្រាប់ពូជ ព្រមទាំងការពារបង្ការភ្លើងព្រៃ និង ចាត់វិធានការ ទប់ស្កាត់គ្រប់រូបភាពអនាធិបតេយ្យក្នុងតំបន់ប្រភពគ្រាប់ពូជឈើនេះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

ប្រការ៣ : ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤ : អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ និង ប្រធានអង្គភាពក្រោមឪវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែ ១០ ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

ច័ន្ទ.សារុន

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាខេត្តរតនគីរី
- ដូចប្រការ ៤
- ឯកសារ - កាលប្បវត្តិ


1504
1504.5
1505
1505.5
1506
1506.5
1507
1507.5
03
04
05
06
07
08
Phum Kôl Pou
BM
216
200
127


1514
1514.5
1515
1515.5
1516
1516.5
1517
1517.5
119
119.5
120
120.5
121
121.5
122
122.5
123
123.5
124
124.5
125
330
350
366
374
390
368


1503.5
1504
1504.5
1505
1505.5
1506
1506.5
1507
235
226
200
BM
216


1519.5
1520
1520.5
1521
1521.5
1522
1522.5
Phum Cha Ung Kraom

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៣៣៣ ប្រក.កសក

ប្រកាស
ស្តីពី
ការបង្កើតតំបន់ប្រមូលគ្រាប់ពូជឈើស្រល់ និង តាត្រាវ
នៅក្នុងខេត្តកំពង់ធំ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ អនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋាន រុក្ខា-ប្រមាញ់ ទៅជា រដ្ឋបាលព្រៃឈើ
- បានឃើញ ប្រកាសលេខ ៥០៥ ប្រក.កសក-បុ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

ស ម្រេ ច

ប្រការ១ : បង្កើតតំបន់ប្រភពគ្រាប់ពូជឈើស្រល់ (*Pinus merkusii* Jungh. et de Vries) និងតាត្រាវ(*Fagraea fragrans* Roxb) មួយ(០១)កន្លែងដែលមានផ្ទៃដីទំហំមួយរយបួន(១០៤) ហិកតា ស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើកំពង់ថ្ម ក្នុងភូមិសាស្ត្រឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានព្រំប្រទល់ ដូចមានកំណត់ក្នុងផែនទីមាត្រដ្ឋាន ១ ៖ ៥០ ០០០ ភ្ជាប់ជាឧបសម្ព័ន្ធ និង មាននិយាមកា: ក (០៥ ៣១ ៦០១; ១៤ ០៩ ៩២៣), ខ (០៥ ៣១ ៣៦៨; ១៤ ០៩ ៧៥៥), គ (០៥ ៣០ ៣៨២; ១៤ ០៩ ៧៥០), ឃ (០៥ ៣០ ២៧៥; ១៤ ០៩ ៩៨៦), ង (០៥ ៣០ ២៨៣; ១៤ ១០ ៣៦៣), ច (០៥ ៣១ ០៤៣; ១៤ ១០ ៧២១) និង ឆ (០៥ ៣១ ៣២៥;១៤ ១០ ៧៤៥) ជាខ្សែព្រំប្រទល់បិទ។ ការបង្កើតតំបន់ប្រភពគ្រាប់ពូជឈើនេះ ក្នុងគោលបំណងអភិរក្ស និង ធ្វើការសិក្សាលើលក្ខណ:សេនេទិក និង ប្រមូលគ្រាប់ពូជសម្រាប់ផ្គត់ផ្គង់ដល់តម្រូវការនៃកម្មវិធីដាំដើមឈើ និង ស្តារព្រៃឈើឡើងវិញ ។

ប្រការ២ : តំបន់ប្រភពគ្រាប់ពូជឈើនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ រដ្ឋបាលព្រៃឈើ ដោយមានភារកិច្ចទទួលខុសត្រូវដូចតទៅ :

- រដ្ឋបាលព្រៃឈើថ្នាក់កណ្តាលមានភារកិច្ចសម្របសម្រួល សិក្សាស្រាវជ្រាវ ផ្សព្វផ្សាយ និង បណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រង ថែរក្សា និង ប្រមូលគ្រាប់ពូជឈើ ស្រល់ និង តាត្រាវក្នុងតំបន់នេះ
- ខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ (ផ្នែករដ្ឋបាលព្រៃឈើកំពង់ថ្ម) មានភារកិច្ចគ្រប់គ្រងថែរក្សា និង ប្រមូលគ្រាប់ពូជ ព្រមទាំងការពារបង្ការភ្លើងព្រៃ និង ចាត់វិធានការទប់ស្កាត់គ្រប់រូបភាពអនាធិបតេយ្យក្នុងតំបន់ប្រភពគ្រាប់ពូជឈើនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

ប្រការ៣ : ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៤ : អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ១០ ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

ចាន់ សារុន

កន្លែងទទួល:

- ទីស្តីការគណ:រដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ធំ
- ដូចប្រការ ៤
- ឯកសារ - កាលប្បវត្តិ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៣៣៤ ប្រក.កសក

ប្រកាស
ស្ដីពី
ការបង្កើតតំបន់ប្រភពគ្រាប់ពូជឈើក្រញូង និង ធ្លង់ នៅក្នុងខេត្តសៀមរាប

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ អនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្ដីពីការប្ដូរឈ្មោះនាយកដ្ឋាន រុក្ខា-ប្រមាញ់ ទៅជា រដ្ឋបាលព្រៃឈើ
- បានឃើញ ប្រកាសលេខ ៥០៩ ប្រក.កសក-ប ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០០៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ

សម្រេច

ប្រការ១ : បង្កើតតំបន់ប្រភពគ្រាប់ពូជឈើចំនួន ពីរ(០២)កន្លែងក្នុងខេត្តសៀមរាប ក្នុងគោលបំណងអភិរក្ស និង ធ្វើការសិក្សាលើលក្ខណៈសេនេទិក និង ប្រមូលគ្រាប់ពូជសម្រាប់ផ្គត់ផ្គង់ដល់តម្រូវការនៃកម្មវិធីដាំដើមឈើ និង ស្តារព្រៃឈើឡើងវិញ ។

តំបន់ទី១: តំបន់ប្រភពគ្រាប់ពូជឈើក្រញូង (*Dalbergia cochinchinensis* Pierre) មានផ្ទៃដីទំហំ ៥០ហិកតា ស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើក្រឡាញ់ ក្នុងភូមិសាស្ត្រឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប ដែលមានព្រំប្រទល់ដូចមានកំណត់ក្នុងផែនទីមាត្រដ្ឋាន ១ ៖ ២៥ ០០០ ភ្ជាប់ជាឧបសម្ព័ន្ធ និង មាននិយាមកា: ក (០៤ ០១ ០៧៨; ១៥ ២០ ៧០០), ខ (០៤ ០១ ២៧៨; ១៥ ២០ ៧១១), គ (០៤ ០១ ២៨៥; ១៥ ២០ ០៦០), ឃ (០៤ ០១ ៣៥៤; ១៥ ១៩ ៩១៩), ង (០៤ ០១ ៣៥៥; ១៥ ១៩ ៨១៦), ច (០៤ ០១ ៧៧១; ១៥ ១៩ ៨៤០), ឆ (០៤ ០១ ៧៨៧; ១៥ ១៩ ៤៧៧), ជ (០៤ ០១ ៦៩០; ១៥ ១៩ ៤៧៧), ឈ (០៤ ០១ ៥៦៤; ១៥ ១៩ ៣៧២), ញ (០៤ ០១ ១០៥; ១៥ ១៩ ៣៦៨) និង ដ (០៤ ០១ ០៣៧; ១៥ ២០ ៦២៥) ជាខ្សែព្រំប្រទល់បិទ។

តំបន់ទី២: តំបន់ប្រភពគ្រាប់ពូជឈើធ្នង់ (*Pterocarpus pedatus* Pierre) មានផ្ទៃដីទំហំ ម្ភៃ (២០) ហិកតា ស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើជីក្រែង ក្នុងភូមិសាស្ត្រឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប ដែលមានព្រំប្រទល់ដូចមានកំណត់ក្នុងផែនទីមាត្រដ្ឋាន ១ ៖ ២៥ ០០០ ភ្ជាប់ជាឧបសម្ព័ន្ធ និង មាននិយាមកា: ក (០៤ ៥១ ១៤០ ១៤ ៨៤ ៦៦៨), ខ (០៤ ៥១ ៥៧៨; ១៤ ៨៤ ៦៧០), គ (០៤ ៥១ ៥៧៨; ១៤ ៨៤ ៧០៨), ឃ (០៤ ៥១ ៧៣៨; ១៤ ៨៤ ៧០៨), ង (០៤ ៥១ ៧៣៨; ១៤ ៨៤ ៣៧៨), ច (០៤ ៥១ ១៤០; ១៤ ៨៤ ៣៧០) ជាខ្សែព្រំប្រទល់បិទ។

ប្រការ២ : តំបន់ប្រភពគ្រាប់ពូជឈើនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ រដ្ឋបាលព្រៃឈើ ដោយមានភារកិច្ច ទទួលខុសត្រូវដូចតទៅ :

- រដ្ឋបាលព្រៃឈើថ្នាក់កណ្តាលមានភារកិច្ចសម្របសម្រួល សិក្សាស្រាវជ្រាវ ផ្សព្វផ្សាយ និង បណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រង ថែរក្សា និង ប្រមូលគ្រាប់ពូជឈើ ក្រញូង និងធ្នង់ក្នុងតំបន់នេះ
- ខ័ណ្ឌរដ្ឋបាលព្រៃឈើសៀមរាប (ផ្នែករដ្ឋបាលព្រៃឈើក្រឡាញ់ និង ជីក្រែង) មានភារកិច្ច គ្រប់គ្រងថែរក្សា និង ប្រមូលគ្រាប់ពូជ ព្រមទាំងការពារបង្ការភ្លើងព្រៃ និង ចាត់វិធានការទប់ស្កាត់គ្រប់រូបភាពអនាធិបតេយ្យក្នុងតំបន់ប្រភពគ្រាប់ពូជឈើនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

ប្រការ៣ : ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤ : អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ១៣ ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

ចាន់ សារុន

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាខេត្តសៀមរាប
- ដូចប្រការ ៤
- ឯកសារ - កាលប្បវត្តិ

ផែនទី ទីតាំងតំបន់ប្រភពក្រាំងពូងឈើក្រញូង
ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប




O Kalai
O Bay
55